ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧

*«ជានាចីរភាពហិរញ្ញវត្ថុសាធារណៈ ដើម្បីពង្រឹងភាពធន់ និងជំរុញកំណើនសេដ្ឋកិច្ច ឆ្ពោះទៅចក្ខុវិស័យឆ្នាំ ២០៥០»*

ខែ មេសា ឆ្នាំ ២០២៤

# មាតិកា


១. បរិការណ៍រួម ........ ១
២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ........ ៣
២.១. បរិការណ៍សេដ្ឋកិច្ចសកល ........ ៣
២.២. ទិដ្ឋភាពសេដ្ឋកិច្ចកម្ពុជា ........ ៥
ក. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០២៣ និងទស្សនវិស័យ ឆ្នាំ ២០២៤ ........ ៥
ខ. ទស្សនវិស័យសេដ្ឋកិច្ចរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧ ........ ១២
គ. ហានិភ័យ និងទិសដៅគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ........ ១៦
៣. យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ ........ ១៨
៣.១. ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ........ ១៨
៣.២. វិធានហិរញ្ញវត្ថុសាធារណៈ ........ ១៩
ក. យុថ្កាហិរញ្ញវត្ថុសាធារណៈ ........ ១៩
ខ. វិធានប្រតិបត្តិ ........ ១៩
៣.៣. អាទិភាពគោលនយោបាយ ........ ២០
៤. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ........ ២១
៤.១. ការអនុវត្តថវិកា ឆ្នាំ ២០២៣ និង ២០២៤ ........ ២១
ក. ការអនុវត្តថវិកា ឆ្នាំ ២០២៣ ........ ២១
ខ. ការប៉ាន់ស្មានការអនុវត្តថវិកាឆ្នាំ ២០២៤ ........ ២២
៤.២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៥-២០២៧ ........ ២៣
ក. ក្របខ័ណ្ឌចំណូល ........ ២៤
ខ. ក្របខ័ណ្ឌចំណាយសាធារណៈ ........ ២៧
គ. ឱនភាពថវិកា និងហិរញ្ញប្បទាន ........ ៣១
៥. ហានិភ័យហិរញ្ញវត្ថុសាធារណៈ ........ ៣២
៥.១. ហានិភ័យម៉ាក្រូសេដ្ឋកិច្ច ........ ៣២
៥.២. ហានិភ័យហិរញ្ញវត្ថុសាធារណៈជាក់លាក់ ........ ៣៣
ក. គម្លាតរវាងការប្រមូលចំណូលជាក់ស្តែងធៀបនឹងការគ្រោង ........ ៣៣
ខ. ការកើននៃបំណុលសាធារណៈ ........ ៣៣
គ. ហានិភ័យពាក់ព័ន្ធទៅនឹងការផ្តល់ឥណទានក្នុងរយៈពេលមធ្យម ........ ៣៣
ឃ. ការកើតមានឡើងនៃបំណុលយថាហេតុ ........ ៣៣
៥.៣. ហានិភ័យស្ថាប័ន ........ ៣៤
ក. ភាពទុកចិត្តបានក្នុងការរៀបចំក្របខ័ណ្ឌ ........ ៣៤
ខ. សមត្ថភាពក្នុងការអនុវត្តក្របខ័ណ្ឌ ........ ៣៤
៦. សេចក្តីសន្និដ្ឋាន ........ ៣៥
ឧបសម្ព័ន្ធ ........ ៣៧
ឧបសម្ព័ន្ធ កៈ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៧ ........ ៣៧
ឧបសម្ព័ន្ធ ខៈ ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ឆ្នាំ ២០២៣-២០២៧ ........ ៣៨
ឧបសម្ព័ន្ធ គៈ ការវិភាគចំណាយថ្នាក់ជាតិតាមវិស័យ ........ ៤០

## ១. បរិការណ៍រួម

ក្រោមឆ័ត្រនៃសុខសន្តិភាព ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ, កម្ពុជា ធានាបាននូវអធិបតេយ្យជាតិ, សណ្តាប់ធ្នាប់សង្គម, សន្តិសុខ, សុវត្ថិភាព និងស្ថិរភាពនយោបាយ ព្រមទាំង រក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ជាលទ្ធផល, កម្ពុជា ត្រូវបានប្រែមុខមាត់ជាថ្មីឡើងវិញ, កសាងបាននូវមូលដ្ឋានគ្រឹះសេដ្ឋកិច្ចរឹងមាំ សម្រាប់កិច្ចអភិវឌ្ឍ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនទូទាំងប្រទេស ។ ក្នុងការកសាងសេដ្ឋកិច្ច, កម្ពុជាបានប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ តាមរយៈ ៖ **១).ការបើកចំហជាបន្តបន្ទាប់នូវ**ការធ្វើពាណិជ្ជកម្មអន្តរជាតិ ឈរលើគោលការណ៍ពហុភាគីនិយម រួមទាំងការធ្វើពិពិធកម្មទីផ្សារ និងទំនិញ ព្រមទាំងការពង្រឹង និងការពង្រីកការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងការជំរុញបន្ថែមនូវការតភ្ជាប់ក្នុងតំបន់; **២).ការជំរុញ និងការទាក់ទាញបន្ថែមនូវការវិនិយោគផ្ទាល់ពីបរទេស** តាមរយៈការកែសម្រួលនូវបរិយាកាសធុរកិច្ច និងវិនិយោគ; **៣).ការពង្រឹង និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរឹង** ដូចជា ផ្លូវ, ថ្នល់, ទឹក និងអគ្គិសនី ដើម្បីលើកកម្ពស់ការតភ្ជាប់ និងភាពប្រកួតប្រជែង; **៤).ការបន្តអភិវឌ្ឍ និងការលើកកម្ពស់មូលធនមនុស្ស** ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងបង្កើនផលិតភាព; និង **៥).ការកែទម្រង់ស្ថាប័ន និងអភិបាលកិច្ច** ជាប្រចាំ សម្រាប់ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ច, ជាពិសេសប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធធនាគារ ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ។ ជាក់ស្តែង, រហូតដល់ដើមនីតិកាលទី ៦ (មុនវិបត្តិជំងឺកូវីដ-១៩), កំណើនសេដ្ឋកិច្ចសម្រេចបានក្នុងកម្រិតខ្ពស់ ជាមធ្យមក្នុងរង្វង់ **៨%** ប្រចាំឆ្នាំ (ទិន្នន័យស៊េរី ផ.ស.ស. ឆ្នាំគោលថ្មី ឆ្នាំ ២០១៤) ដែលផ្លែផ្កានៃកំណើននេះ បានចូលរួមបង្កើតការងារជូនប្រជាពលរដ្ឋ, លើកកម្ពស់ជីវភាពរស់នៅ និងប្រាក់ចំណូល, និងកាត់បន្ថយភាពក្រីក្រ ព្រមទាំងកសាងមូលដ្ឋានគ្រឹះសង្គម-សេដ្ឋកិច្ចកម្ពុជា ឱ្យកាន់តែប្រសើរឡើងជាលំដាប់ ។ ជាអកុសល, ចាប់ពីពាក់កណ្តាលនីតិកាលទី ៦ ពោលពីឆ្នាំ ២០២០ មក, កម្ពុជា ក៏ដូចជាប្រទេសផ្សេងទៀតទូទាំងពិភពលោក បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩ ដែលជាវិបត្តិសុខភាពសកលដ៏កាចសាហាវ សាយភាយឥទ្ធិពលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលមកទល់បច្ចុប្បន្នបានបន្សល់ស្លាកស្នាមនៃឥទ្ធិពល (Scarring Effects) នៅឡើយ ។ ទោះជាយ៉ាងនេះក្តី, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, រាជរដ្ឋាភិបាល បានយកជ័យជម្នះលើសមរភូមិនេះ ដោយម្ខាង, ដណ្តើមបានជោគជ័យលើការគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩; និងម្ខាងទៀត, បានជួយស្រោចស្រង់វិស័យឯកជន ឱ្យបន្តអាជីវកម្ម និងជំរុញសកម្មភាពសេដ្ឋកិច្ច និងធុរកិច្ច ក៏ដូចជារក្សានូវលំនឹងជីវភាពរស់នៅរបស់កម្មករ-និយោជិត និងប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ។ ជាលទ្ធផល, សកម្មភាពសង្គម-សេដ្ឋកិច្ចកម្ពុជា បានវិលត្រលប់ទៅរកប្រក្រតីភាព បន្ទាប់ពីការបើកប្រទេសទាំងស្រុងឡើងវិញ ចាប់ពីចុងឆ្នាំ ២០២១ ហើយសេដ្ឋកិច្ចក៏ត្រូវបានស្តារឡើងវិញជាបន្តបន្ទាប់ ទោះបីជាវិបត្តិសកលផ្សេងទៀត កើតមានម្តងហើយម្តងទៀត ។

ក្នុងនីតិកាលទី ៧ នេះ, រាជរដ្ឋាភិបាលកម្ពុជា, ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងថាមវន្ត របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយឈរលើស្មារតី «**រក្សាសមិទ្ធផលចាស់, បង្កើតសមិទ្ធផលថ្មី**» និង «**គិតគូរជាសកល និងអនុវត្តតាមបរិការណ៍ក្នុងប្រទេស (Think Globally and Act Locally)**», បន្តខិតខំដោះស្រាយបញ្ហាប្រឈមនានា ដើម្បីសម្របខ្លួន និងឆ្លើយតបប្រកបដោយបុរេសកម្ម ឱ្យទាន់សភាពការណ៍សង្គម-សេដ្ឋកិច្ចសកល និងតំបន់, និងជាពិសេសចាប់ឱ្យជាប់នូវកាលានុវត្តភាព ដែលអាចលេចចេញក្នុងបរិការណ៍នៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មសង្គម-សេដ្ឋកិច្ច

សកល ។ ក្នុងគោលដៅនេះ, រាជរដ្ឋាភិបាលអាណត្តិទី ៧ បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បី **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និង ចីរភាព** និងកំណត់យកនូវ **អាទិភាពគន្លឹះ ចំនួន ៥ ៖ មនុស្ស, ផ្លូវ, ទឹក, ភ្លើង និង បច្ចេកវិទ្យា** ។

ដើម្បីបន្តរក្សាបាននូវចលនការកំណើនសេដ្ឋកិច្ចខ្ពស់ ក៏ដូចជាសម្រេចបាននូវសមិទ្ធផលថ្មីបន្ថែមទៀត, ការដាក់ចេញ និងអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ (Fiscal Policy), ប្រកបដោយភាពប្រុងប្រយ័ត្ន និងភាពប៉ាន់ប្រមាណបាន ព្រមទាំងដោយការធានានូវចីរភាព គឺជាការចាំបាច់មិនអាចខ្វះបាន ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងដាក់ចេញនូវ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម** ដែលបង្ហាញពីការព្យាករយៈពេលមធ្យមនូវទស្សនវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, កំណត់យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ (Fiscal Strategy) និងកំណត់នូវ **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ (Fiscal Policy Stance)** ដោយប្រកាន់ខ្ជាប់នូវ **វិធានហិរញ្ញវត្ថុសាធារណៈមួយចំនួន** (Fiscal Rules) ។

ការរៀបចំ **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២៥-២០២៧»** ត្រូវបានធ្វើឡើងក្រោមទម្រង់ ៣ ឆ្នាំរំកិល (Three Years Rolling) ដែលក្នុងនោះ ពិតានថវិកាដាក់លាក់ឆ្នាំ ២០២៥ (ដែលជាឆ្នាំទី ១) នឹងជាផ្នែកមួយនៃការរៀបចំច្បាប់ថវិកាឆ្នាំ ២០២៥, ខណៈដែលចំណោលសម្រាប់ឆ្នាំ ២០២៦ (ឆ្នាំទី ២) និងឆ្នាំ ២០២៧ (ឆ្នាំទី ៣) នឹងអាចត្រូវបានកែតម្រូវនៅឆ្នាំបន្តបន្ទាប់ ដើម្បីឱ្យស្របទៅតាមការប្រែប្រួលនៃស្ថានភាពសង្គម-សេដ្ឋកិច្ចក្នុងស្រុក និងបរិយាកាសសេដ្ឋកិច្ចខាងក្រៅ ។ ក្របខ័ណ្ឌនេះនឹងក្លាយជាមូលដ្ឋានសម្រាប់ការ-រៀបចំនូវ **«ក្របខ័ណ្ឌថវិការយៈពេលមធ្យម ២០២៥-២០២៧»** និង **«សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការ-គ្រប់គ្រងឆ្នាំ ២០២៥»** ។

ជាការគិតគូរ, ឆ្នាំ ២០២៥ និងរយៈពេលមធ្យមទៅមុខ គឺជាដំណាក់កាលដែលកម្ពុជាបន្តដំណើរលើមាគ៌ាស្តារ និងជំរុញកំណើនឡើងវិញ បន្ទាប់ពីទទួលរងការប៉ះទង្គិចផ្ទួនៗពីវិបត្តិបន្តបន្ទាប់ក្នុងឆ្នាំកន្លងមក, ប៉ុន្តែកំណើនមិនទាន់ស្ថិតលើគន្លងសក្តានុពលនៅឡើយ; ខណៈស្ថានភាពនយោបាយ, សេដ្ឋកិច្ច និងសង្គម, ទាំងសកល, តំបន់, និងក្នុងស្រុក, ត្រូវបានរំពឹងទុកថានឹងកាន់តែមានភាពប្រសើរឡើង ។ ក្នុងដំណាក់កាលនេះ, ការ-វាយតម្លៃទស្សនវិស័យសេដ្ឋកិច្ច ស្ថិតក្រោមសម្មតិកម្មថា ស្ថានភាពសង្គម-សេដ្ឋកិច្ចនៃប្រទេសជាដៃគូសំខាន់របស់កម្ពុជា នឹងវិវត្តកាន់តែវិជ្ជមាន ហើយភាពតានតឹងគោលនយោបាយ និងវិបត្តិនានា នឹងមានភាពធូរស្បើយ ដែលនឹងជះឥទ្ធិពលល្អ មកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា ស្របពេលចលនការនៃការកែទម្រង់ស៊ីជម្រៅក្នុងប្រទេសនឹងបន្តហុចផលជាផ្លែផ្កា និងរួមចំណែកជាវិជ្ជមាន ដល់ដំណើរការអភិវឌ្ឍន៍ជារួម ។ ក្រោមសម្មតិកម្មនេះ, កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករក្នុងរង្វង់ **៦,៣%** សម្រាប់ ២០២៥ និងជាមធ្យម ៦,៦% សម្រាប់ឆ្នាំ ២០២៦-២០២៧ ។ យ៉ាងណាមិញ, ហានិភ័យ និងភាពមិនប្រាកដប្រជា, ទាំងក្នុងក្របខ័ណ្ឌសកល, តំបន់, និងក្នុងស្រុក, នៅតែអាចមានលទ្ធភាពកើតឡើងខ្ពស់ ដែលនឹងធ្វើឱ្យសម្មតិកម្មខាងលើអាចមិនប្រែក្លាយជាតថភាពជាក់ស្តែង, និងផ្លាស់ប្តូរនូវក្របខ័ណ្ឌដែលបានរៀបចំនេះ ។

ប្រាកដណាស់, កម្ពុជានឹងមិនអាចត្រៀមវិធានការគោលនយោបាយ សម្រាប់គ្រប់សេណារីយ៉ូដែលអាចកើតមានឡើងនោះទេ ជាមួយនឹងសភាពការណ៍សកលដែលមានការវិវត្តយ៉ាងហ័ស, ពោរពេញទៅដោយភាព-មិនប្រាកដប្រជាខ្ពស់, និងមិនចំណុះនឹងការគ្រប់គ្រងរបស់កម្ពុជា ។ ក្នុងន័យនេះ, **ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** នឹងប្រកាន់ខ្ជាប់នូវ **អភិក្រម ២** ទន្ទឹមគ្នាសម្រាប់ការគ្រប់គ្រងសភាពការណ៍ រួមមាន ៖ **ម្វាង,** តាមដាន, សិក្សា និងវាយតម្លៃ ជាប់ជាប្រចាំ លើដំណើរការវិវត្តនៃស្ថានការណ៍ខាងក្រៅ និងផ្ទៃក្នុងប្រទេស ពោល

គឺ ត្រូវភ្ជាប់ជាប់ជាប្រចាំនូវជីពចរនៃសេដ្ឋកិច្ច និងសង្គម និងត្រូវដាក់ចេញ, ដោយបុរេសកម្ម និងទាន់ពេល, នូវវិធានការចាំបាច់ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាព ទៅនឹងបញ្ហាប្រឈម និងហានិភ័យទាំងឡាយដែលកើតមានចំពោះមុខ, ពិសេស វិធានការសំដៅធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពវិស័យហិរញ្ញវត្ថុ និងលំនឹងនៃជីវភាពប្រជាជន, និង **ម្យ៉ាងទៀត,** ហ៊ានវះកាត់ និងដាក់ចេញនូវវិធានការដាក់លាក់, មុតស្រួច និងចំគោលដៅ ដើម្បីដោះស្រាយបញ្ហាជាឧបសគ្គរាំងស្ទះទាំងឡាយ សំដៅលើកកម្ពស់ភាពប្រកួតប្រជែង និងពង្រឹងភាពធន់ ដើម្បីទាក់ទាញ និងជំរុញការវិនិយោគ និងលើកកម្ពស់សកម្មភាពសេដ្ឋកិច្ច ជាទូទៅ ។

ម្យ៉ាងវិញទៀត, ការរៀបចំ «**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧**» ក៏ផ្អែកផងដែរ លើលទ្ធផលនៃការផ្លាស់ប្តូរឆ្នាំគោលថ្មីនៃគណនេយ្យជាតិ ឆ្នាំ ២០១៤ សម្រាប់ការគណនាស៊េរីទិន្នន័យផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ។ ការផ្លាស់ប្តូរឆ្នាំគោលថ្មីនៃគណនេយ្យជាតិ បានធ្វើឱ្យមានការរីកនៃទំហំសេដ្ឋកិច្ច និងការផ្លាស់ប្តូររចនាសម្ព័ន្ធនៃវិស័យពិត (Real Sector) ដែលបង្កើតជាបច្ច័យ មកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ និងសូចនាករតាមវិស័យផ្សេងទៀតជាអនុបាតនៃ ផ.ស.ស. រួមមាន ៖ វិស័យហិរញ្ញវត្ថុសាធារណៈ (Fiscal Sector), វិស័យខាងក្រៅ (External Sector) និងវិស័យរូបិយវត្ថុ (Monetary Sector) ។

គួរគូសបញ្ជាក់ថា, ការដាក់ចេញឱ្យអនុវត្តនូវ «**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧**» ជាផ្លូវការ គឺអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ជាផ្នែកមួយនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបច្ចុប្បន្នកំពុងស្ថិតក្នុងការអនុវត្តដំណាក់កាលទី ៤ គឺ «**គណនេយ្យភាពសមិទ្ធកម្ម» (២០២១-២០២៥)** ក្នុងគោលបំណង ៖ **(១)**-គាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល; **(២)**-ពង្រឹងប្រសិទ្ធភាពនៃការវិភាជថវិកា; និង **(៣)**-ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ។ ម្យ៉ាងវិញទៀត, ការដាក់ចេញនូវក្របខ័ណ្ឌខាងលើ ស្របតាម **យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥** ដោយមានគោលបំណងពង្រឹងវិន័យថវិកា ចាប់តាំងពីការរៀបចំផែនការរហូតដល់ការវិភាជ និងការអនុវត្តថវិកា តាមរយៈការផ្សារភ្ជាប់ថវិកាទៅគោលនយោបាយអាទិភាព និងការវិភាជថវិកាដោយផ្អែកលើព័ត៌មានសមិទ្ធកម្ម ដែលមានធាតុសំខាន់ៗ ៣ គឺ ៖ (១). ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម; (២). ក្របខ័ណ្ឌថវិការយៈពេលមធ្យម; និង (៣). ក្របខ័ណ្ឌសមិទ្ធកម្មរយៈពេលមធ្យម ។

# ២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

## ២.១. បរិការណ៍សេដ្ឋកិច្ចសកល

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ, ស្ថានភាពសេដ្ឋកិច្ច បាននិងកំពុងបន្តប្រឈមនឹងហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ ជាមួយនឹងផលប៉ះពាល់ ដែលបង្កឡើងដោយឥទ្ធិពលផ្គួនគ្នា (Cumulative Effect) ពីវិបត្តិធំៗមួយចំនួន ដូចជា ៖ ស្លាកស្នាមនៃវិបត្តិជំងឺកូវីដ-១៩, សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន, និងការផ្ទុះឡើងនូវការប្រយុទ្ធរវាងអ៊ីស្រាអែល និងក្រុមហាម៉ាស់ (Israel and Hamas Conflict) ជាដើម ។ បន្ថែមលើនេះ, ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល និងសម្ពាធអតិផរណា បានបង្កផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ចសកល ផងដែរ ។ តាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), កំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០២៣ ត្រូវបានរំពឹងថា ថមថយមកនៅ ក្នុងរង្វង់ ៣,២% ។

ក្នុងឆ្នាំ ២០២៤ នេះ, ស្ថានភាពសេដ្ឋកិច្ចសកលនឹងបន្តកំណើនក្នុងលក្ខណៈទ្រឹង **៣,២%** ដូចឆ្នាំ ២០២៣ ក្នុងបរិបទអន្តរកាលនៃពហុវិបត្តិ ពោលគឺវិបត្តិមួយមិនទាន់ឆ្លងផុត, វិបត្តិមួយទៀតកើតមានជាបន្តបន្ទាប់;

សង្គ្រាមមួយមិនទាន់ឃើញទីបញ្ចប់ផង, សង្គ្រាមមួយទៀតក៏ផ្ទុះឡើងថែមទៀត ។ វិបត្តិផ្ទួនៗ និងផលជះស្ដែងចេញពីការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល នៅតែបន្តដាក់សម្ពាធដល់កំណើនសេដ្ឋកិច្ចសកល, ខណៈដែលកំណើននៅតាមបណ្ដាប្រទេសនីមួយៗ កំពុងងើបវិញក្នុងល្បឿនខុសគ្នា (Growing Global Divergences) ពោលគឺ អាស្រ័យលើបរិការណ៍ និងលក្ខខណ្ឌសេដ្ឋកិច្ចផង និងអាស្រ័យលើការដាក់ចេញនូវគោលនយោបាយនានា និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយទាំងនោះផង ។ ក្នុងនោះ, បណ្ដាប្រទេសសេដ្ឋកិច្ចអភិវឌ្ឍន៍ (Developed Economies) បាននិងកំពុងប្រឈមនឹងកំណើនសេដ្ឋកិច្ចដែលថមថយ ជាងបណ្ដាប្រទេសមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ (Emerging and Developing Economies) ។

## តារាងទី ១៖ កំណើនសេដ្ឋកិច្ចសកល និងតំបន់

| | សេដ្ឋកិច្ចសកល | ប្រទេសអភិវឌ្ឍន៍ | សេដ្ឋកិច្ចកំពុងរីកលូតលាស់ និងប្រទេសកំពុងអភិវឌ្ឍ | សហរដ្ឋអាម៉េរិក | តំបន់ចាយប្រាក់អឺរ៉ូ | ចក្រភពអង់គ្លេស | ជប៉ុន | ចិន | អាស៊ាន-៥ |
|---|---|---|---|---|---|---|---|---|---|
| 2022 | 3.5 | 2.6 | 4.1 | 1.9 | 3.4 | 4.3 | 1.0 | 3.0 | 5.5 |
| 2023 | 3.2 | 1.6 | 4.3 | 2.5 | 0.4 | 0.1 | 1.9 | 5.2 | 4.1 |
| 2024 | 3.2 | 1.7 | 4.1 | 2.7 | 0.8 | 0.5 | 0.9 | 4.6 | 4.5 |
| 2025 | 3.2 | 1.8 | 4.2 | 1.9 | 1.5 | 1.5 | 1.0 | 4.1 | 4.6 |
| 2026 | 3.2 | 1.8 | 4.1 | 2.0 | 1.4 | 1.7 | 0.8 | 3.8 | 4.6 |
| 2027 | 3.1 | 1.7 | 4.0 | 2.1 | 1.3 | 1.7 | 0.6 | 3.6 | 4.6 |

ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ទស្សនវិស័យសេដ្ឋកិច្ចសកល ខែ មេសា ឆ្នាំ ២០២៤

ទោះជាយ៉ាងនេះក្ដី, សម្រាប់រយៈពេលខ្លី និងមធ្យមខាងមុខ, សេដ្ឋកិច្ចសកលនៅបន្តហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ រួមមាន ៖ **(១).** ភាពតានតឹងនៃកត្តាភូមិសាស្ត្រនយោបាយ/សេដ្ឋកិច្ច, ជាក់ស្ដែងដូចជាការផ្ទុះឡើងនូវជម្លោះនៅតំបន់សមុទ្រក្រហម ជាដើម ដែលអាចបន្ទប់បង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកល; **(២).** ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម; **(៣).** ការងើបវិញនៃថ្លៃទំនិញអន្តរជាតិ ដែលបង្កឡើងដោយភាពតានតឹងនៃកត្តាភូមិសាស្ត្រនយោបាយ/សេដ្ឋកិច្ច; **(៤).** និន្នាការកំណើនទាបនៃសេដ្ឋកិច្ចសកល, ជាពិសេសកំណើនសេដ្ឋកិច្ចចិន; **(៥).** ការបន្តកើនសម្ពាធបំណុលសាធារណៈ; និង **(៦).** ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។ យ៉ាងណាមិញ, ក្រោមការអនុវត្តគោលនយោបាយរឹតបន្តឹងរូបិយវត្ថុកន្លងទៅនេះ, សម្ពាធអតិផរណាសកលលោក, ជាពិសេសនៅតាមបណ្ដាប្រទេសអភិវឌ្ឍន៍, មានការថមថយមកវិញដោយរំពឹងថានឹងអាចវិលត្រលប់ទៅរកអត្រាគោលដៅ (ប្រមាណ ២%) ជាបណ្ដើរៗនៅក្នុងឆ្នាំ ២០២៥ ដែលប្រការនេះត្រូវបានរំពឹងថានឹងអាចជួយជំរុញតម្រូវការក្នុងស្រុក និងសកម្មភាពវិនិយោគឱ្យងើបសន្សឹមៗមកវិញផងដែរ ។ **ក្នុងរយៈពេលមធ្យម (២០២៥-២០២៧), សេដ្ឋកិច្ចសកលអាចនឹងបន្តកំណើន ក្នុងរង្វង់ ៣,២% ដោយសារការរំពឹងទុកនៃការថមថយនៃផលប៉ះពាល់ពីវិបត្តិ (Gradual Dying Out of Shocks) និងការត្រលប់ទៅរកប្រក្រតីភាពវិញនៃអត្រាអតិផរណាសកល ។**

## ២.២. និន្នាការសេដ្ឋកិច្ចកម្ពុជា

### ក. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០២៣ និងទស្សនវិស័យ ឆ្នាំ ២០២៤

ដូចគ្នាទៅនឹងស្ថានភាពសេដ្ឋកិច្ចតំបន់ និងសកល, សេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃថាមានកំណើនក្នុងរង្វង់ ៥,០% ក្នុងឆ្នាំ ២០២៣ ប្រហាក់ប្រហែលទៅនឹងកំណើនក្នុងឆ្នាំ ២០២២ ក្នុងអត្រា ៥,១% ។ កំណើននេះ ត្រូវបានគាំទ្រយ៉ាងសំខាន់ពីការបន្តនិន្នាការល្អនៃវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងការបន្តងើបវិញ ក៏ដូចជាការរក្សាបាននូវចលនការនៃវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ ព្រមទាំងវិស័យគាំទ្រផ្សេងទៀត (វិស័យទេសចរណ៍), ទោះបីវិស័យកាត់ដេរបានទទួលការប៉ះទង្គិចពីការធ្លាក់នៃតម្រូវការខាងក្រៅ យ៉ាងណាក្តី ។ គួរបញ្ជាក់ថា, ការបន្តអនុវត្តវិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ក៏បានចូលរួមចំណែកដ៏សំខាន់ផងដែរ ក្នុងការរក្សាលំនឹងជីវភាពប្រជាជនទូទៅ និងស្ថិរភាពអាជីវកម្ម ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាស្ថិរភាពសង្គម-សេដ្ឋកិច្ច ជារួម ។

**ក្រាហ្វិកទី ១៖ កំណើន ផ.ស.ស. ឆ្នាំ ២០១៧-២០២៧**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១៧-២០២២) និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៣-២០២៧)

សម្រាប់ឆ្នាំ ២០២៤, សេដ្ឋកិច្ចកម្ពុជា ត្រូវបានប៉ាន់ស្មានថានឹងងើបវិញ ក្នុងអត្រាកំណើន ៦,០% ដោយសារការត្រលប់ទៅរកភាពល្អឡើងវិញនៃសេដ្ឋកិច្ចសកល, ជាពិសេសប្រទេសដៃគូពាណិជ្ជកម្មកម្ពុជា, ស្របពេលដែលសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកនៅបន្តរក្សាស្ថិរភាព និងនិន្នាការល្អ ។ ការពង្រឹងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានា, ជាពិសេសការពន្លឿនការអនុវត្ត **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** និងកម្មវិធីគោលនយោបាយអាទិភាពនានា ជាមួយនឹងការបន្តពង្រឹងការកែទម្រង់ស៊ីជម្រៅ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក, ទាំងលើការស្តារវិស័យចន្ទល់កំណើនដែលមានស្រាប់, ក៏ដូចជាលើកកម្ពស់វិស័យសក្តានុពលថ្មីៗមួយចំនួនទៀត, រួមមានការវិនិយោគលើសហគ្រាសធុនតូច និងមធ្យម, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង, នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការជំរុញ និងបង្កើនតម្លៃបន្ថែមដល់សេដ្ឋកិច្ច ។

## ■ វិស័យឧស្សាហកម្ម

**វិស័យឧស្សាហកម្ម** ត្រូវបានវាយតម្លៃថាមានកំណើនថមថយពីអត្រា ៨,២% ក្នុងឆ្នាំ ២០២២ មកត្រឹមអត្រា ៤,៣% ក្នុងឆ្នាំ ២០២៣ ដោយសារការធ្លាក់នៃអនុវិស័យកាត់ដេរ និងកំណើនយឺតនៃអនុវិស័យសំណង់ ដែលបានបំពេញមកវិញមួយផ្នែកដោយកំណើនប្រសើរនៃអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ, អនុវិស័យផលិតកម្មម្ហូបអាហារ និងអនុវិស័យផលិតកម្មភេសជ្ជៈ និងថ្នាំជក់ ។ សម្រាប់ឆ្នាំ ២០២៤, វិស័យឧស្សាហកម្ម នឹងងើបវិញ ក្នុងរង្វង់ ៧,៩% ដោយសារការងើបវិញនៃអនុវិស័យកាត់ដេរ ស្របពេលដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងអនុវិស័យផលិតកម្មម្ហូបអាហារ និងភេសជ្ជៈ នៅបន្តរក្សាបានចលនការ ។



**អនុវិស័យកាត់ដេរ** ត្រូវបានវាយតម្លៃថាសម្រេចបានកំណើនអវិជ្ជមាន ក្នុងអត្រា -៣,៥% ក្នុងឆ្នាំ ២០២៣ ដោយសារការធ្លាក់ជាងការរំពឹងទុកនៃតម្រូវការខាងក្រៅ, ជាពិសេសបណ្តាប្រទេសដែលជាដៃគូពាណិជ្ជកម្មកម្ពុជា ដូចជា៖ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប, ដែលបង្កឡើងដោយវិបាកនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ។ សម្រាប់ឆ្នាំ ២០២៤, អនុវិស័យកាត់ដេរត្រូវបានប៉ាន់ស្មានថានឹងមានកំណើនងើបវិញ ក្នុងអត្រា ៧,៥% ដោយសារការងើបជាសន្សឹមៗនៃតម្រូវការសកល ស្របពេលដែលសម្ពាធអតិផរណាមានភាពស្រាកស្រាន្ត ។



**អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ** ត្រូវបានប៉ាន់ស្មានថានឹងបន្តរក្សាបាននូវកំណើនរឹងមាំក្នុងអត្រា ១៧,០% ក្នុងឆ្នាំ ២០២៣ ដោយសារការបន្តកើននៃតម្រូវការខាងក្រៅ ស្របពេលដែលផលិតផលបម្រើឱ្យទីផ្សារក្នុងស្រុក បន្តកើន ជាពិសេសលើផ្នែកចំណីអាហារ និងភេសជ្ជៈ, គ្រឿងបរិក្ខារអេឡិចត្រូនិក និងផ្នែកដំឡើងរថយន្ត ជាដើម ។ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ រំពឹងថានឹងសម្រេចបានកំណើនរឹងមាំក្នុងអត្រា ១៣,០% ក្នុងឆ្នាំ ២០២៤ ដោយសារការរំពឹងបន្តកើននៃតម្រូវការខាងក្រៅ និងតម្រូវការក្នុងស្រុក ដែលគាំទ្រដោយការងើបវិញនៃវិស័យទេសចរណ៍ ស្របនឹងការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុកជាបន្តបន្ទាប់ ។ លើសពីនេះ, សកម្មភាពផលិតកម្មបម្រើឱ្យការនាំចេញ (គ្រឿងសង្ហារិម, សំបកកង់, គ្រឿងបង្គុំអេឡិចត្រូនិក និងសូឡា) រំពឹងថានឹងបន្តមានសក្តានុពល ជាពិសេសការនាំចេញទៅទីផ្សារសហរដ្ឋអាមេរិក, ចិន និងទីផ្សារក្នុងតំបន់ រួមទាំង អាស៊ាន ជាដើម ។ ជាមួយគ្នានេះ, សកម្មភាពផលិតកម្មបម្រើឱ្យទីផ្សារក្នុងស្រុក ក៏នៅបន្តរក្សាបានចលនការល្អ, ជាពិសេសទ្រទ្រង់ដោយផលិតកម្មកែច្នៃផលិតផល និងដំឡើងរថយន្តបម្រើទីផ្សារក្នុងស្រុក ។ តាមការពិភាក្សា, ក្នុងឆ្នាំ ២០២៤, ក្រុមហ៊ុនដំឡើងរថយន្តក្នុងស្រុកមួយ គ្រោងនឹងដំឡើងរថយន្តក្នុងរង្វង់ ប្រមាណ ៦ ០០០-៧ ០០០ គ្រឿង កើនពី ប្រមាណ ៤ ០០០ គ្រឿង ក្នុងឆ្នាំ ២០២៣ ហើយគ្រោងជ្រើសរើសកម្លាំងពលកម្ម និងពង្រីកសកម្មភាពផលិតកម្មបន្ថែមទៀត ។ ទន្ទឹមនឹងនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ និងគោលនយោបាយមួយចំនួន ដូចជា «**ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា**» សំដៅបង្កើនភាពទាក់ទាញនៃបរិយាកាសវិនិយោគ, បន្តជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការមុតស្រួច ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហា

ជារចនាសម្ព័ន្ធ និងបញ្ហាផ្សេងៗ ដែលមានចរិតអន្តរស្ថាប័ន សំដៅលើកកម្ពស់ផលិតកម្មក្នុងស្រុក ។

**អនុវិស័យសំណង់** ត្រូវបានវាយតម្លៃថានឹងបន្តមានកំណើនទាប ក្នុងអត្រា ០,៧% សម្រាប់ឆ្នាំ ២០២៣ ដោយសារការបន្តថមថយសកម្មភាពសំណង់ថ្លៃខ្ពស់ រួមមាន ៖ ខុនដូ និងអាផាតមិន និងសំណង់បម្រើឱ្យវិស័យពាណិជ្ជកម្ម និងទេសចរណ៍ ស្របពេលដែលសកម្មភាពសំណង់លំនៅឋានថ្លៃទាប និងមធ្យមក៏មានការថមថយជាងការរំពឹងទុកផងដែរ ។ សំណង់ថ្លៃខ្ពស់បន្តនៅទ្រឹង ដោយសារសំណង់ប្រភេទនេះពឹងផ្អែកខ្លាំងលើលំហូរនៃការវិនិយោគពីបរទេស ។ ជាមួយគ្នានេះ, សំណង់លំនៅឋានថ្លៃទាប និងមធ្យម ដែលជាចន្ទល់កំណើនសំខាន់សម្រាប់វិស័យនេះជារួម ក៏មាននិន្នាការថមថយផងដែរ, មួយផ្នែកធំដោយសារការបន្តថមថយតម្រូវការទិញ-លក់ និងបញ្ហាលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋាន ។ ក្រៅពីសំណង់លំនៅឋាន, សកម្មភាពសាងសង់ប្រភេទផ្សេងៗទៀត ដូចជា សំណង់បម្រើឱ្យផ្សារលក់រាយតម្លៃខ្ពស់ (Prime High Street) និងសំណង់បម្រើឱ្យសកម្មភាពឧស្សាហកម្ម និងសេវាកម្មផ្សេងទៀត គឺនៅមានសកម្មភាព និងជួយទ្រទ្រង់កំណើនវិស័យសំណង់ ។ អនុវិស័យសំណង់ក្នុងឆ្នាំ ២០២៤ ត្រូវបានប៉ាន់ស្មានថានឹងងើបឃើញ ក្នុងអត្រាកំណើនប្រមាណ ១,១%ដោយសារការរំពឹងទុកការបន្តសកម្មភាពសំណង់លំនៅឋានថ្លៃទាប និងមធ្យម និងការងើបវិញជាបណ្តើរៗនៃលំហូរទុនវិនិយោគពីបរទេស ដែលស្របនឹងនិន្នាការសេដ្ឋកិច្ច ។ គួរបញ្ជាក់ថា, ទស្សនវិស័យនៃអនុវិស័យនេះនឹងមិនអាចមានកំណើនខ្ពស់ដូចមុនវិបត្តិជំងឺកូវីដ-១៩ ដែលការវិនិយោគ និងភាគច្រើននៃតម្រូវការកន្លងមក ត្រូវបានជំរុញដោយសកម្មភាពបរិកប្បកម្ម (Speculation) ។ ការដាក់ចេញវិធានការទាំង ៨ ចំណុចរបស់រាជរដ្ឋាភិបាល និងវិធានការបន្ថែមក្នុងវេទិការាជរដ្ឋាភិបាល-វិស័យឯកជនលើកទី ១៩ កន្លងទៅ បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការរក្សាលំនឹងអាជីវកម្មរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ ដែលអាចធានានូវការរស់-រានបានក្នុងកាលៈទេសៈដ៏លំបាកនេះ ។

**អនុវិស័យផលិតកម្មម្ហូបអាហារ** និង **អនុវិស័យផលិតកម្មឱសថៈ និងថ្នាំជក់** ត្រូវបានវាយតម្លៃថាសម្រេចបានកំណើន ៧,៣% និង ៦,៨% រៀងគ្នា ក្នុងឆ្នាំ ២០២៣ ដែលគាំទ្រដោយការ-ងើបវិញនៃសកម្មភាពទេសចរណ៍ ស្របពេលដែលការរៀបចំព្រឹត្តិការណ៍ និងពិធីបុណ្យជាតិក្នុងស្រុកផ្សេងៗ ជំរុញដល់កំណើននៃសកម្មភាពប្រើប្រាស់ និងការហូបចុក ហើយនឹងបន្តកំណើន ៧,៧% ដូចគ្នាសម្រាប់ឆ្នាំ ២០២៤ ។ កំណើននេះ គាំទ្រដោយគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញឧស្សាហកម្មធុនតូច និងមធ្យម និងនិន្នាការផ្លាស់ប្តូរនៃឥរិយាបទរបស់ប្រជាជនបែបប្រពៃណី ទៅទីផ្សារបែបទំនើប ដូចជា៖ ផ្សារទំនើប, ហាង, និងកន្លែងលក់អាហារជាដើម និងការកើននូវការទទួលទានឱសថៈ សម្រាប់សុខភាព និងឱសថៈគ្មានជាតិអាល់កុល ។ ក្នុងការជំរុញការអភិវឌ្ឍអនុវិស័យនេះ, រាជរដ្ឋាភិបាលបានបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ដើម្បីផ្តល់ហិរញ្ញប្បទានក្នុងលក្ខខណ្ឌអនុគ្រោះ និងអត្រាការប្រាក់ទាបដល់សហគ្រាសក្នុងវិស័យអាទិភាព ខណៈ «មូលនិធិអភិវឌ្ឍន៍ជំនាញ» និង

«មូលនិធិសហគ្រិនភាព» ក៏ត្រូវបានផ្តួចផ្តើមឡើង ដើម្បីពង្រឹងផលិតភាពផលិតកម្ម តាមរយៈការបង្កើនគុណភាពជំនាញ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងគម្លាតការផ្គត់ផ្គង់ជំនាញ និងតម្រូវការកម្លាំងពលកម្មលើទីផ្សារ ក៏ដូចជាបង្កើតប្រព័ន្ធអេកូឡូស៊ីចាំបាច់ ។ ជាមួយគ្នានេះ, ការកើនចំនួនប្រជាជន និងចំណូល (ទីផ្សារក្នុងស្រុក) ក៏នឹងទាក់ទាញវិនិយោគបរទេស និងក្នុងតំបន់ ក្នុងការបង្កើនការវិនិយោគក្នុងវិស័យនេះនាពេលខាងមុខ, ខណៈការពង្រឹងការអនុវត្តគោលនយោបាយនានា នឹងជួយជំរុញការអភិវឌ្ឍវិស័យនេះ, ជាពិសេសជួយពង្រឹងផលិតភាព និងអនុលោមភាពរបស់សហគ្រាសតូច និងមធ្យម ។

## ■ វិស័យសេវាកម្ម

**វិស័យសេវាកម្ម** ត្រូវបានវាយតម្លៃថានឹងកើន ៧,២% ក្នុងឆ្នាំ ២០២៣ គាំទ្រដោយសារការបន្តនិន្នាការកើននៃអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ និងសេវាកម្មគាំទ្រទេសចរណ៍ផ្សេងទៀត ដូចជាអនុ-វិស័យដឹកជញ្ជូន និងស្តុក និងអនុវិស័យលក់ដុំ-រាយ ជាដើម ។ សម្រាប់ឆ្នាំ ២០២៤, វិស័យនេះ រំពឹងថានឹងបន្តរក្សាចលនការកំណើនក្នុងរង្វង់ ៥,៨% ដោយសារការបន្តរក្សាកំណើនល្អនៃអនុវិស័យគាំទ្រទេសចរណ៍ ខណៈដែលអនុវិស័យអចលនទ្រព្យបន្តកំណើនទាប ។

**អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ** ត្រូវបានវាយតម្លៃថាបន្តងើបវិញល្អ ក្នុងអត្រា ៤៧,៥% ក្នុងឆ្នាំ ២០២៣ ដែលអត្រានេះផ្តើមចេញពីមូលដ្ឋានទាប (Low Base) ដែលបានធ្លាក់ពីរឆ្នាំជាប់គ្នា ពោលគឺឆ្នាំ ២០២០ និង ២០២១ ។ គួរបញ្ជាក់ថា, កំណើននេះទ្រទ្រង់ដោយការងើបវិញនៃទេសចរអន្តរជាតិ និងទេសចរជាតិដែលជាលទ្ធផលនៃ ៖ (១). ការស្តារឡើងវិញនូវទំនុកចិត្តក្នុងការធ្វើដំណើររបស់ទេសចរមកកម្ពុជា; (២). ការលុបចោលរបាំងនានា ដែលរឹតបន្តឹងការធ្វើដំណើរផ្សេងៗទាំងក្នុងប្រទេស, សកល, និង តំបន់; និង (៣). ការប្រារព្ធព្រឹត្តិការណ៍កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេមក្នុងឆ្នាំ ២០២៣ ។ សម្រាប់ឆ្នាំ ២០២៤, អនុវិស័យនេះ ត្រូវបានប៉ាន់ស្មានថានឹងកើន ១២,៦% ដោយសារការរំពឹងទុកនៃនិន្នាការបន្តងើបនៃទេសចរអន្តរជាតិ និងទេសចរជាតិ ។ កំណើននៃអនុវិស័យនេះ ទ្រទ្រង់ដោយការយកចិត្តទុកដាក់កាន់តែខ្លាំងក្នុងការបន្តលើកស្ទួយ ក៏ដូចជាការផ្សព្វផ្សាយកាន់តែទូលំទូលាយពីគោលដៅទេសចរណ៍កម្ពុជា ទៅកាន់ឆាកអន្តរជាតិ, ការបង្កើនការតភ្ជាប់ជើងហោះហើរត្រង់ពីប្រទេសដែលជាគោលដៅទេសចរណ៍, និងកិច្ចសហប្រតិបត្តិការលក្ខណៈអន្តរ-ក្រសួង និងជាមួយស្ថាប័នឯកជន ក្នុងការរៀបចំយុទ្ធសាស្ត្រនានាពាក់ព័ន្ធវិស័យទេសចរណ៍ និងដោះស្រាយបញ្ហាចំពោះមុខ ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ខ្ពស់លើការជំរុញការអភិវឌ្ឍវិស័យនេះ តាមរយៈការដាក់ចេញនូវកម្មវិធីពិសេស គឺ ៖ **«ទស្សនាសៀមរាប ឆ្នាំ ២០២៤»** សំដៅជំរុញឱ្យវិស័យទេសចរណ៍នៅក្នុងខេត្តសៀមរាប; ការបង្កើតឡើងនូវយន្តការអន្តរស្ថាប័ន **«ក្រុមប្រឹក្សាទេសចរណ៍»** ដោយមានការចូលរួមពីស្ថាប័នរដ្ឋ និងវិស័យឯកជនពាក់ព័ន្ធ សំដៅដោះស្រាយនូវបញ្ហាប្រឈមនានាទាន់ពេល; ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់; ការបង្កើតប្រភេទតម្រូវការថ្មីៗ; ការកសាងសមត្ថភាពដើម្បីគាំទ្រ

តម្រូវការនាពេលអនាគត; និងការជំរុញការធ្វើបរិវត្តកម្មក្នុងវិស័យទេសចរណ៍ រួមជាមួយនឹងការបន្តអនុវត្តផែនការមេអភិវឌ្ឍន៍ខេត្តទេសចរណ៍នានា ។

**អនុវិស័យអចលនទ្រព្យ** ត្រូវបានវាយតម្លៃថាមិនមានកំណើន ក្នុងឆ្នាំ ២០២៣ ដោយសារការបន្តនៅទ្រឹងនៃចរន្តទិញ-លក់ និងជួលអចលនវត្ថុ និងរំពឹងថាងើបក្នុងល្បឿនយឺត ក្នុងរង្វង់ ១,២% សម្រាប់ឆ្នាំ ២០២៤ ។ ចរន្តទិញ-លក់ និងជួលអចលនវត្ថុថ្លៃខ្ពស់, ពិសេសផ្នែកខុនដូ, បន្តនិន្នាការថមថយ ដោយហេតុថាតម្រូវការអចលនវត្ថុប្រភេទនេះពឹងផ្អែកខ្លាំងលើភ្ញៀវទេសចរអន្តរជាតិ (បែបធុរកិច្ច) ។ ទោះជាយ៉ាងនេះក្តី, សកម្មភាពអចលនវត្ថុជារួមក៏នៅបន្តទ្រទ្រង់ដោយសកម្មភាព ជួលអគារផ្សារលក់រាយ (Retail Mall) ។ ដូចគ្នានឹងវិស័យសំណង់ដែរ, ការដាក់ចេញនូវវិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាលកន្លងមក ក៏បានចូលរួមចំណែកជួយរក្សាលំនឹងអាជីវកម្មរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ ក៏ដូចជាកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរ និងបានចូលរួមរក្សាលំនឹងដល់វិស័យនេះ រួមជាមួយនឹងការរំពឹងទុកការងើបជាបណ្តើរៗនៃចរន្តទិញ-លក់ និងជួលអចលនវត្ថុ ស្របនឹងនិន្នាការសេដ្ឋកិច្ច ។

**អនុវិស័យលក់ដុំ-រាយ** ត្រូវបានវាយតម្លៃថានឹងមានកំណើនថមថយក្នុងអត្រា ៤,០% ក្នុងឆ្នាំ ២០២៣ ដែលឆ្លុះបញ្ចាំងពីការថមថយនៃសកម្មភាពនាំចូល និងទិញ-លក់លើទំនិញមួយចំនួន ដោយសារការធ្លាក់នូវអំណាចទិញរបស់ប្រជាជន, ពិសេស ទៅលើទំនិញប្រណិតដូចជារថយន្ត ជាដើម; ប៉ុន្តែត្រូវបានប៉ះប៉ូវមកវិញដោយសកម្មភាពចាយវាយក្នុងស្រុកលើទំនិញម្ហូបអាហារ និងភេសជ្ជៈ និងទំនិញចាំបាច់មួយចំនួនទៀត ស្របពេលនឹងការងើបវិញនៃវិស័យទេសចរណ៍ និងការប្រារព្ធព្រឹត្តិការណ៍ជាតិ និងអន្តរជាតិនានា ។ សម្រាប់ឆ្នាំ ២០២៤, អនុវិស័យនេះត្រូវបានរំពឹងថានឹងបន្តកើនក្នុងអត្រា ៥,៣% ដែលទ្រទ្រង់ដោយការបន្តកើននូវសកម្មភាពចាយវាយក្នុងស្រុក ក៏ដូចជាការបន្តនិន្នាការល្អនៃវិស័យទេសចរណ៍ ស្របពេលដែលមានការកើននៃការប្រើប្រាស់ប្រព័ន្ធឌីជីថល និងពាណិជ្ជកម្មអេឡិចត្រូនិក (E-Commerce) គួបផ្សំនឹងគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាល ។

**អនុវិស័យដឹកជញ្ជូន និងស្តុក** ត្រូវបានវាយតម្លៃថានឹងមានកំណើនក្នុងអត្រា ៤,៧% ក្នុងឆ្នាំ ២០២៣ ដែលគាំទ្រដោយសកម្មភាពល្អនៃវិស័យទេសចរណ៍ និងវិស័យសេវាកម្មគាំទ្រផ្សេងទៀត រួមមាន ការកើននូវនិន្នាការនៃការប្រើសេវាឡជីស្ទីកក្នុងស្រុក ដូចជា ការដឹកជញ្ជូនទំនិញរហ័សក្នុងស្រុក (Express Service) និងការដឹកជញ្ជូនទំនិញគោលដៅចុងក្រោយដល់អ្នកប្រើប្រាស់ (Last-Mile Delivery) ។ អនុវិស័យដឹកជញ្ជូន និងស្តុក ត្រូវបានរំពឹងថានឹងបន្តមានកំណើន ៥,២% ក្នុងឆ្នាំ ២០២៤ ដោយសារការបន្តរក្សាចលនការនៃសកម្មភាពដឹកជញ្ជូន រួមបញ្ចូលទាំងការដឹកជញ្ជូនបែបឡជីស្ទីក, ជាពិសេសការងើបវិញនៃអនុវិស័យគាំទ្រដល់ការដឹកជញ្ជូន ដូចជាអនុវិស័យកាត់ដេរ ជាដើម ។ រាជរដ្ឋាភិបាលនឹងបន្តជំរុញការរៀបចំតំបន់ត្រួតពិនិត្យរួមគ្នានៅតាមច្រកទ្វារព្រំដែន ដើម្បីសម្រួលចរាចរណ៍ទំនិញ និងមនុស្ស, ជំរុញការអភិវឌ្ឍប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ និងកែសម្រួលនីតិវិធី ដើម្បីកាត់បន្ថយឯកសារ និងចំណាយដឹកជញ្ជូន, បន្តពង្រីកសមត្ថភាពផ្ទុកកុងតឺន័រនៅទីលានចំណតផែ, បន្តពង្រីក និងធ្វើ

ទំនើបកម្មកំពង់ផែស្វយ័តក្រុងព្រះសីហនុ, និងជំរុញអនុវត្ត **«ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូន អន្តរមធ្យោបាយ និងភស្តុភារកម្មកម្ពុជា ២០២៣-២០៣៣»** ។

**អនុវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍** ត្រូវបានវាយតម្លៃថានឹងមានកំណើនក្នុងអត្រា ៩,០% ក្នុងឆ្នាំ ២០២៣ ដែលឆ្លុះបញ្ចាំងពីការបន្តកើនឡើងនូវចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត ក៏ដូចជាទំហំអ៊ីនធឺណិតដែលប្រើប្រាស់ តាមរយៈការបន្ថែមបង្គោលប្រព័ន្ធទូរស័ព្ទចល័ត និងការប្រារព្ធព្រឹត្តិការណ៍កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ។ សម្រាប់ឆ្នាំ ២០២៤, អនុវិស័យនេះត្រូវបានរំពឹងថានឹងបន្តកំណើនជាមធ្យម ក្នុងអត្រា ៨,០% ទ្រទ្រង់ដោយការរំពឹងទុកនូវការបន្តកើននូវចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត និងទំហំអ៊ីនធឺណិតដែលប្រើប្រាស់, ការបន្តបន្ថែមបង្គោល និងពង្រីកវិសាលភាពគ្របដណ្តប់នៃប្រព័ន្ធទូរស័ព្ទ និងអ៊ីនធឺណិតលើផ្ទៃប្រទេស, និងការលេចឡើងនូវដំណោះស្រាយបច្ចេកវិទ្យាថ្មី (Technology Solutions) ដែលនឹងបង្កើនតម្លៃបន្ថែមសម្រាប់អនុវិស័យនេះ, គួបផ្សំនឹងការអនុវត្តគោលនយោបាយ ដូចជា **«គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨»**, **«គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥»**, **«ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥»** ។ល។

**អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង** ត្រូវបានវាយតម្លៃថាមានកំណើនអវិជ្ជមានក្នុងឆ្នាំ ២០២៣ ក្នុងអត្រា -៤,០% ដោយសារការធ្លាក់ប្រាក់ចំណេញរបស់វិស័យហិរញ្ញវត្ថុផ្នែកធនាគារ (ធនាគារពាណិជ្ជ), ខណៈដែលការផ្តល់ឥណទានមានការថមថយខ្លាំង ស្របនឹងការកើននូវថ្លៃដើមឥណទាន ។ ការណ៍នេះ បណ្តាលមកពីការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល, ពិសេសគឺធនាគារកណ្តាលរបស់សហរដ្ឋអាមេរិក ។ យ៉ាងណាមិញ, អនុវិស័យធានារ៉ាប់រងនៅបន្តរក្សាបានចលនការកំណើន ប៉ុន្តែក្នុងអត្រាថមថយដែរ ។ ក្នុងឆ្នាំ ២០២៤, អនុវិស័យនេះ រំពឹងថានឹងងើបវិញ ក្នុងអត្រាកំណើន ០,១% ក្រោមការរំពឹងទុកការធ្លាក់មកវិញជាបណ្តើរៗនៃថ្លៃដើមឥណទាន ដោយសារការបន្ធូរបន្ថយការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល ។

## ■ វិស័យកសិកម្ម

**វិស័យកសិកម្ម** ក្នុងឆ្នាំ ២០២៣ ត្រូវបានវាយតម្លៃថាមានការកើន ០,៩% គាំទ្រដោយកំណើននៃអនុវិស័យដំណាំ និងអនុវិស័យចិញ្ចឹមសត្វ, ខណៈអនុវិស័យនេសាទបន្តសម្រេចបានកំណើនទាប ។ សម្រាប់ឆ្នាំ ២០២៤, វិស័យកសិកម្ម ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនយឺតក្នុងអត្រា ០,៧% ឆ្លុះបញ្ចាំងពីភាពលំបាកសម្រាប់វិស័យចិញ្ចឹមសត្វ និងនេសាទ ដោយសារការធ្លាក់នៃថ្លៃលក់ ដែលបានធ្វើឱ្យផលិតកទទួលរងការខាតបង់, ប៉ុន្តែអនុវិស័យដំណាំ នៅតែរឹងមាំសម្រាប់គាំទ្រកំណើននៃវិស័យកសិកម្ម ជារួម ។

**អនុវិស័យដំណាំ** ត្រូវបានវាយតម្លៃថាកើនក្នុងរង្វង់ ១,៣% ក្នុងឆ្នាំ ២០២៣ ដោយសារកំណើនផលិតកម្មស្រូវ ក៏ដូចជាដំណាំសាកវប្បកម្ម និងឧស្សាហកម្ម, ជាពិសេសដំឡូងមី និងកៅស៊ូ ដែលជំរុញដោយកត្តាថ្លៃល្អ ។ សម្រាប់ឆ្នាំ ២០២៤, អនុវិស័យនេះត្រូវបានប៉ាន់ស្មានថាមាន

កំណើន ១,៦% ដោយសារកំណើននៃផលិតកម្មទាំងសម្រាប់តម្រូវការក្នុងស្រុក និងបម្រើការនាំចេញ ដែលគាំទ្រដោយកត្តាថ្លៃ, ការបន្តងើបនៃវិស័យទេសចរណ៍, ការបន្តកើននៃសកម្មភាពសេដ្ឋកិច្ច និងការជួយជ្រោមជ្រែងពីរាជរដ្ឋាភិបាល តាមរយៈការផ្តល់ហិរញ្ញប្បទាន និងវិធានការផ្សេងៗ ។



**អនុវិស័យចិញ្ចឹមសត្វ** ត្រូវបានវាយតម្លៃថាមានកំណើនទាបក្នុងរង្វង់ ០,៩% ក្នុងឆ្នាំ ២០២៣ ដោយសារថ្លៃធាតុចូលខ្ពស់ ដែលធ្វើឱ្យផលចំណេញទាប, ជាពិសេសការចិញ្ចឹមតាមបែបគ្រួសារ, ស្របពេលដែលការនាំចូលសាច់បង្កកក៏បានដាក់សម្ពាធបន្ថែម មកលើថ្លៃសាច់ក្នុងទីផ្សារ ។ សម្រាប់ឆ្នាំ ២០២៤, អនុវិស័យនេះត្រូវបានប៉ាន់ស្មានថាធ្លាក់ក្នុងអត្រា -២,០% ដោយសារផលិតករមួយចំនួនកាត់បន្ថយផលិតកម្ម សម្រាប់ឆ្នាំនេះ ។ យ៉ាងណាមិញ, ការដាក់ចេញវិធានការបន្ទាន់លើការផ្អាកការនាំចូលសាច់បង្កក និងការអនុវត្តអនុក្រឹត្យ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងជាប់កម្រិតកំណត់នឹងជួយបង្កើនទំនុកចិត្តដល់ផលិតកម្មក្នុងស្រុក ហើយអាចធ្វើឱ្យអនុវិស័យនេះ មានភាពប្រសើរជាងការរំពឹងទុក ។



**អនុវិស័យនេសាទ** ត្រូវបានវាយតម្លៃថាងើបបន្តិចមកវិញក្នុងអត្រា ០,១% ក្នុងឆ្នាំ ២០២៣ និងបន្តងើបសន្សឹមៗ ក្នុងអត្រា ០,២% សម្រាប់ឆ្នាំ ២០២៤ ដែលគាំទ្រដោយការងើបវិញនៃផលចាប់ទឹកសាប តាមរយៈប្រសិទ្ធភាពនៃការពង្រឹងវិធានការបង្ក្រាបបទល្មើសនេសាទ ខណៈផលិតកម្មវារីវប្បកម្មនៅបន្តប្រឈមនឹងបញ្ហាទីផ្សារផ្គត់ផ្គង់ ។

## ■ អតិផរណា និងអត្រាប្តូរប្រាក់

ក្នុងឆ្នាំ ២០២៣, អត្រាអតិផរណាមានការថមថយមកក្នុងរង្វង់ ២,១% ពីប្រមាណ ៥,៣% ក្នុងឆ្នាំ ២០២២ ដោយសារការត្រលប់ទៅរកប្រក្រតីភាពជាបណ្តើរៗនៃថ្លៃទំនិញអន្តរជាតិ, ជាពិសេស ថ្លៃប្រេង ។ ទោះជាយ៉ាងនេះក្តី, អត្រាប្តូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាម៉េរិក) បានកើនដល់ប្រមាណ ៤ ១១០ រៀល/ដុល្លារអាម៉េរិក ដោយសារការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាម៉េរិក ដែលបណ្តាលឱ្យរូបិយប័ណ្ណដុល្លារអាម៉េរិកឡើងថ្លៃ ធៀបនឹងរូបិយប័ណ្ណផ្សេងៗ រួមបញ្ចូលទាំងប្រាក់រៀលផងដែរ ។ ក្នុងឆ្នាំ ២០២៤, អត្រាអតិផរណា នឹងបន្តមានកំណើនក្នុងរង្វង់ ២,៧% ដោយសារការបន្តងើបវិញនៃសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក, ស្របពេលដែលថ្លៃទំនិញអន្តរជាតិនៅបន្តរក្សាបានស្ថិរភាព ។ អត្រាប្តូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាម៉េរិក) រំពឹងថានឹងធ្លាក់មកត្រឹមប្រមាណ ៤ ០៨៣ រៀល/ដុល្លារអាម៉េរិក ដោយសារការរំពឹងទុកពីការបន្ធូរបន្ថយការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ គួបផ្សំនឹងវិធានការអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពប្រាក់រៀល ។

## ■ វិស័យខាងក្រៅ

សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ស្មានថានឹងមានអតិរេក, ដែលប្លែកជាងនិន្នាការធម្មតា, ក្នុងរង្វង់ប្រមាណ ១,៣% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៣, ធៀបនឹងប្រមាណ -១៨,៩% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២២, ដោយសារការធ្លាក់នៃការនាំចូល, ជាពិសេសការធ្លាក់យ៉ាងគំហុកនៃការនាំចូលមាស, វត្ថុធាតុដើមផលិតកម្ម, និងការនាំចូលយានយន្ត ។ ផ្ទុយទៅវិញ, ការនាំចេញរបស់កម្ពុជា នៅបន្តរក្សាបានកំណើនវិជ្ជមាន

ដោយការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ និងផលិតផលកសិកម្ម បើទោះបីការនាំចេញផលិត-ផលកាត់ដេរបានធ្លាក់យ៉ាងណាក្តី ។ ជាមួយគ្នានេះ, ចំណូលពីវិស័យទេសចរណ៍ ក៏បានបន្តងើប ដែលឆ្លុះបញ្ចាំងពីការបន្តនិន្នាការកើននៃភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងការងើបវិញនៃវិស័យទេសចរណ៍ ជារួម ។ លំហូរវិនិយោគផ្ទាល់ពីបរទេស នៅបន្តនិន្នាការកើន ក្នុងរង្វង់ប្រមាណ ៣ ៩៥៩ លានដុល្លារអាម៉េរិក ឬ ប្រមាណ ៩,២% នៃ ផ.ស.ស., ជាមួយនឹងកំណើនប្រមាណ ១០,៦% ធៀបនឹងឆ្នាំ ២០២២ ដែលត្រូវបានជំរុញដោយការ-វិនិយោគក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ ដូចជា ៖ ផលិតកម្មសំបកកង់រថយន្ត, សូឡា, ផលិតផលវេចខ្ចប់, ចំណីអាហារកែច្នៃ និងសំបកកំប៉ុង, និងលោហធាតុ ជាដើម ស្របពេលដែលការវិនិយោគក្នុងវិស័យធនាគារនៅបន្តរក្សាបានចលនការល្អ ។ ការណ៍នេះ ធ្វើឱ្យទុនបម្រុងអន្តរជាតិពូនគរ ក្នុងរង្វង់ ១៩ ៩៩៨ លានដុល្លារអាម៉េរិក ដែលស្មើនឹងប្រមាណ ៨,២ ខែនៃការនាំចូល ។

ក្នុងឆ្នាំ ២០២៤, សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) រំពឹងថានឹងត្រលប់ទៅរកនិន្នាការធម្មតាវិញ ពោលគឺមានឱនភាព ក្នុងរង្វង់ -១,៥% នៃ ផ.ស.ស. ដោយសារការរំពឹងទុកការងើបវិញនៃការនាំចូល ជារួម ។ ការ-នាំចេញ ក៏រំពឹងថានឹងបន្តងើប និងរក្សាបាននូវចលនការ ដែលនឹងបន្តជំរុញដោយការនាំចេញផលិតផលកម្មន្ត-សាលមិនមែនកាត់ដេរ និងការងើបវិញនៃការនាំចេញផលិតផលកាត់ដេរ ។ ជាមួយគ្នានេះ, ចំណូលពីវិស័យទេសចរណ៍ក៏នឹងបន្តនិន្នាការកើន ដោយសារការរំពឹងទុកការបន្តកើននៃភ្ញៀវទេសចរ, ស្របនឹងការដាក់ចេញនូវវិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាអាទិ៍ **«ទស្សនាសៀមរាប ២០២៤»** ។ល។ លំហូរវិនិយោគផ្ទាល់ពីបរទេសរំពឹងថានឹងបន្តកើន ដល់ប្រមាណ ៤ ២៥០ លានដុល្លារអាម៉េរិក ឬ ប្រមាណ ៩,០% នៃ ផ.ស.ស. ដោយសារការបន្តសកម្មភាពវិនិយោគលើវិស័យសក្តានុពល ។ ទន្ទឹមនេះ, ទុនបម្រុងអន្តរជាតិ ត្រូវបានព្យាករថានឹងបន្តកើន ក្នុងរង្វង់ ២២ ៣០៣ លានដុល្លារអាម៉េរិក ឬ ស្មើប្រមាណ ៨,០ ខែ នៃការនាំចូល ។

## ខ. ទស្សនវិស័យសេដ្ឋកិច្ចរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧

ក្នុងរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧, កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថាស្ថិត**ក្នុងអត្រាជាមធ្យម ៦,៥% ក្នុងនោះឆ្នាំ ២០២៥ ព្យាករថាមានកំណើន ៦,៣%** ក្រោមការរំពឹងទុកនៃនិន្នាការល្អនៃតម្រូវការសកល និងកំណើនទំនុកចិត្តវិនិយោគិនបរទេស, ស្របពេលដែលលក្ខខណ្ឌហិរញ្ញវត្ថុសកលអាចប្រសើរឡើង ។ ទន្ទឹមនេះ, ការពង្រឹងការអនុវត្ត **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»** និងឆន្ទៈក្នុងការកែទម្រង់ស៊ីជម្រៅ និងមុតស្រួច របស់រាជរដ្ឋាភិបាល នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការដោះស្រាយបញ្ហារចនាសម្ព័ន្ធ ដែលមានភាពប្រទាក់ក្រឡា សំដៅជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការកសាងមូលធនមនុស្ស, ពង្រឹងអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច, បង្កើនផលិតភាពផលិតកម្ម, ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទដោយបូកបញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល ក្នុងការឈានទៅបង្កើត និងចាប់យកវិស័យកំណើនថ្មីដោយផ្អែកលើជំនាញ, បច្ចេក-វិទ្យា និងនវានុវត្តន៍ ។



**វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យមប្រមាណ ៨,៩% សម្រាប់រយៈពេលមធ្យម ២០២៥-២០២៧ **ក្នុងនោះឆ្នាំ ២០២៥ ព្យាករថាមានកំណើន ៨,៦%** គាំទ្រដោយការរក្សាបានតុល្យភាពនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈអនុវិស័យសំណង់នៅបន្តមានកំណើនទាបជាងនិន្នាការធម្មតា (មុនវិបត្តិជំងឺកូវីដ-១៩) ។ អនុវិស័យកាត់ដេរ ត្រូវបានរំពឹងថានៅបន្តរក្សាបានកំណើនប្រហាក់ប្រហែលមុនវិបត្តិជំងឺកូវីដ-

១៩ ដោយសារភាពប្រសើរនៃតម្រូវការសកល គួបផ្សំនឹងការពង្រឹងការអនុវត្ត **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧»** ដែលនឹងលើកកម្ពស់បរិយាកាសវិនិយោគ និងភាពប្រកួតប្រជែង ជាមួយនឹងការបង្កើនផលិតភាពពលកម្ម ។ ជាមួយគ្នានេះ, អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ត្រូវបានព្យាករថានឹងបន្តរក្សាបានកំណើនរឹងមាំ ដោយសារការរំពឹងពីការបន្តកើននៃតម្រូវការខាងក្រៅ ដែលនឹងបន្តជំរុញការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ស្របពេលដែលឧស្សាហកម្មបម្រើឱ្យទីផ្សារក្នុងស្រុក ត្រូវបានរំពឹងថានឹងបន្តកើន ក្រោមការដាក់ចេញនូវវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល សំដៅជំរុញសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព ។ ស្របគ្នានេះ, អនុវិស័យផលិតកម្មម្ហូបអាហារ និងភេសជ្ជៈ ក៏ត្រូវបានព្យាករថានឹងបន្តកំណើនល្អ ។ ទោះជាយ៉ាងនេះក្ដី, អនុវិស័យសំណង់ ត្រូវបានព្យាករថាបន្តកំណើនទាបជាងនិន្នាការធម្មតា ដោយសារការរំពឹងពីការងើបវិញយឺតនៃលំហូរវិនិយោគទុនពីបរទេស, ជាពិសេសសំណង់បម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម, ស្របពេលដែលសំណង់លំនៅឋាន ត្រូវបានរំពឹងថាបន្តរក្សាកំណើនទាប ធៀបនឹងនិន្នាការមុនវិបត្តិជំងឺកូវីដ-១៩ ។ ក្នុងរយៈពេលមធ្យមខាងមុខ, អនុវិស័យនេះនឹងជំរុញដោយសកម្មភាពសំណង់ដែលចេញពីតម្រូវការពិត, ជាពិសេស ផ្នែកលំនៅឋាន ដែលគាំទ្រដោយសារភាពប្រសើរនៃកត្តាភាគលាភប្រជាសាស្ត្រកម្ពុជា, ខណៈដែលសំណង់បម្រើឱ្យឧស្សាហកម្ម, រោងចក្រ និងសកម្មភាពពាណិជ្ជកម្មផ្សេងទៀត ក៏នឹងក្លាយជានិន្នាការថ្មីមួយជួយទ្រទ្រង់វិស័យនេះក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ ។

**វិស័យសេវាកម្ម** ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យមប្រមាណ ៥,៧% ប្រហាក់ប្រហែលគ្នាទៅនឹងនិន្នាការធម្មតា សម្រាប់រយៈពេលមធ្យម ២០២៥-២០២៧ **ក្នុងនោះឆ្នាំ ២០២៥ ព្យាករថាមានកំណើន ៥,៦%** ដោយសារការបន្តរក្សាបានចលនការនៃអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ និងសេវាកម្មទេសចរណ៍គាំទ្រផ្សេងទៀត, ខណៈដែលអនុវិស័យអចលនទ្រព្យនៅបន្តមានកំណើនទាប ។ អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ ត្រូវបានរំពឹងថានឹងបន្តកើន គាំទ្រដោយភ្ញៀវទេសចរអន្តរជាតិ, ខណៈភ្ញៀវទេសចរជាតិនៅបន្តមានសក្តានុពល ។ ការបន្តអនុវត្តនូវ **«ផែនទីចង្អុលផ្លូវស្ដីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩»**, **«ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥»** និង **«ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ២០២១-២០៣៥»** និង កម្មវិធី **«ទស្សនាសៀមរាប ២០២៤»** នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការស្តារ និងជំរុញកំណើនវិស័យទេសចរណ៍ឡើងវិញ ។ អនុវិស័យអចលនទ្រព្យ ត្រូវបានរំពឹងថានឹងកើនក្នុងអត្រាទាបជាងធម្មតា ដោយសារការរំពឹងទុកនៃការបន្តងើបវិញយឺតនៃលំហូរទុនវិនិយោគពីបរទេស ប៉ុន្តែសកម្មភាពទិញ-លក់អចលនទ្រព្យ ជាពិសេសផ្នែកលំនៅឋានថ្លៃទាប និងមធ្យម រំពឹងថានឹងបន្តគាំទ្រដល់កំណើននៃអនុវិស័យនេះ ជារួម ។ អនុវិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងបន្តកើនប្រហាក់ប្រហែលទៅនឹងនិន្នាការធម្មតា ដោយសារការរំពឹងទុកពីការងើបវិញនៃសកម្មភាពចាយវាយ និងតម្រូវការក្នុងស្រុក ស្របជាមួយនឹងនិន្នាការនៃការកើនប្រាក់ចំណូលរបស់ប្រជាជន ។ ការផ្លាស់ប្តូរសកម្មភាពអាជីវកម្មតាមរយៈការប្រើប្រាស់

ឌីជីថល នឹងអាចជួយលើកកម្ពស់បន្ថែមទៀតដល់អនុវិស័យនេះជារួម ។ អនុវិស័យដឹកជញ្ជូន និងស្តុក ត្រូវបានរំពឹងថានឹងបន្តកំណើនរឹងមាំ ដោយសកម្មភាពដឹកជញ្ជូនកាន់តែមានភាពមមាញឹក, ជាពិសេសការដឹកជញ្ជូនទំនិញក្នុងស្រុក (Express Service) និងការដឹកជញ្ជូនទំនិញគោលដៅចុងក្រោយដល់អ្នកប្រើប្រាស់ (Last-Mile Delivery) ។ ទន្ទឹមនេះ, ការដាក់ចេញនូវចក្ខុវិស័យក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន រួមមាន ផ្លូវអាកាស, ផ្លូវទឹក, និងផ្លូវគោក, តាមរយៈ **«ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្មកម្ពុជា ២០២៣-២០៣៣»** នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើននៃអនុវិស័យនេះ ។ អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង នៅបន្តរក្សាបានចលនការ ដែលគាំទ្រដោយការបន្តធ្វើទំនើបកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ សំដៅបម្រើដល់តម្រូវការប្រជាជន និងអាជីវកម្ម, ខណៈដែលការអនុវត្ត **«គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨»** និង **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០១៦-២០២៥»** នឹងដើរតួនាទីសំខាន់ក្នុងការបន្តជំរុញការធ្វើទំនើបកម្ម និងបរិយាប័ន្នវិស័យហិរញ្ញវត្ថុ ពោលទាំងផ្នែកធនាគារ និងមិនមែនធនាគារ ។ អនុវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ត្រូវបានព្យាករថាបន្តកើនប្រហាក់ប្រហែលទៅនឹងនិន្នាការធម្មតា ដោយសារការបន្តកើននៃសកម្មភាពប្រើប្រាស់អ៊ីនធឺណិត និងការផ្តល់សេវានូវដំណោះស្រាយបច្ចេកវិទ្យាថ្មី (Technology Solutions) ស្របជាមួយនឹងការបន្តអនុវត្ត **«គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨»**, **«គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥»**, **«ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥»** ។ល។

**វិស័យកសិកម្ម** ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យមប្រមាណ ១,២% ប្រហាក់ប្រហែលនិន្នាការកន្លងទៅ សម្រាប់រយៈពេលមធ្យម **ក្នុងនោះឆ្នាំ ២០២៥ ព្យាករថាមានកំណើន ១,១%** ដោយសារការរំពឹងទុកនូវកំណើនល្អនៃអនុវិស័យដំណាំ និងចិញ្ចឹមសត្វ និងការងើបសន្សឹមៗនៃអនុវិស័យនេសាទ ។ អនុវិស័យដំណាំ ត្រូវបានរំពឹងថានៅរក្សាកំណើនល្អ ដោយសារការបន្តកើននៃការវិនិយោគទាំងក្នុងស្រុក និងពីបរទេសលើការកែច្នៃផលិតផលកសិកម្ម, ការបង្កើនវិនិយោគសាធារណៈ និងអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដូចជា ៖ ការផ្តល់ហិរញ្ញប្បទានសម្បទាន ក្នុងការជំរុញផលិតកម្មក្នុងស្រុក និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ដែលនឹងបន្តជំរុញដល់ការនាំចេញ ។ ទន្ទឹមនេះ, អនុវិស័យចិញ្ចឹមសត្វ ត្រូវបានព្យាករថានឹងបន្តងើបសន្សឹមៗ ដោយសារវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល លើការនាំចូលសាច់បង្កក ដែលនឹងលើកទឹកចិត្តការចិញ្ចឹមក្នុងស្រុក ខណៈអនុវិស័យនេសាទ ត្រូវបានព្យាករថានឹងមានកំណើនល្អ ក្រោមការរំពឹងទុកនូវកំណើនផលចាប់ទឹកសាប ដែលបន្តស្តារឡើងវិញដោយការដាក់ចេញនូវគោលនយោបាយបង្ក្រាបបទល្មើសនេសាទ និងការវិនិយោគក្នុងវារីវប្បកម្ម រំពឹងថានឹងងើបសន្សឹមៗ ដោយសារការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍តាមរយៈការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ, ការគាំទ្រផ្នែកហិរញ្ញប្បទាន, ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់ និងគុណភាព ។

ក្នុងរយៈពេលមធ្យមខាងមុខ (២០២៥-២០២៧), **អត្រាអតិផរណា** ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ២,៥% ដោយសារការរក្សាបាននូវចលនការសេដ្ឋកិច្ចក្នុងស្រុក និងប្រក្រតីភាពនៃស្ថានភាព និងថ្លៃទំនិញអន្តរជាតិ ស្របពេលដែល **អត្រាប្តូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាមេរិក)** រំពឹងថារក្សាបានក្នុងរង្វង់ជាមធ្យម ៤ ០៦០ រៀល/ដុល្លារអាមេរិក ។

## តារាងទី ២៖ ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាតាមវិស័យ ឆ្នាំ ២០១៩-២០២៧

| កំណើន (%) | 2019 | 2020 | 2021 | 2022 | 2023ប. | 2024ព្យ. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|---|---|---|---|
| **ផ.ស.ស.** | **7.9** | **-3.6** | **3.1** | **5.1** | **5.0** | **6.0** | **6.3** | **6.5** | **6.7** |
| **វិស័យកសិកម្ម** | **-0.4** | **0.6** | **1.5** | **0.6** | **0.9** | **0.7** | **1.1** | **1.2** | **1.3** |
| ដំណាំ | 0.6 | 0.9 | 2.2 | 1.1 | 1.3 | 1.6 | 1.6 | 1.7 | 1.8 |
| នេសាទ | -2.6 | 0.9 | 2.3 | 1.2 | 0.9 | -2.0 | 0.3 | 0.5 | 0.6 |
| ចិញ្ចឹមសត្វ | -1.5 | 0.7 | -1.0 | -1.3 | 0.1 | 0.2 | 0.3 | 0.4 | 0.5 |
| **វិស័យឧស្សាហកម្ម** | **13.0** | **-2.2** | **8.4** | **8.2** | **4.3** | **7.9** | **8.6** | **9.1** | **9.5** |
| កាត់ដេរ | 12.9 | -7.7 | 15.9 | 11.3 | -3.5 | 7.5 | 9.4 | 9.1 | 8.8 |
| សំណង់ | 18.7 | -7.6 | -8.0 | 0.9 | 0.7 | 1.1 | 2.5 | 4.0 | 5.8 |
| ផលិតកម្មម្ហូបអាហារ | 7.8 | 3.4 | 4.2 | 7.6 | 7.3 | 7.7 | 7.5 | 6.7 | 6.5 |
| ផលិតកម្មភេសជ្ជៈ និងថ្នាំជក់ | 7.7 | 4.4 | 7.9 | 5.6 | 6.8 | 7.7 | 8.4 | 8.9 | 9.4 |
| កម្មន្តសាលមិនមែនកាត់ដេរ | 8.4 | 11.9 | 16.8 | 10.3 | 17.0 | 13.0 | 11.7 | 11.7 | 11.7 |
| **សេវាកម្ម** | **6.6** | **-6.7** | **-1.8** | **3.6** | **7.2** | **5.8** | **5.6** | **5.9** | **5.8** |
| បដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ | 5.5 | -34.2 | -39.5 | 22.0 | 47.5 | 12.6 | 8.4 | 7.3 | 5.1 |
| លក់ដុំ-រាយ | 5.7 | -6.3 | 2.5 | 4.5 | 4.0 | 5.3 | 5.9 | 6.1 | 6.3 |
| ដឹកជញ្ជូន និងស្តុក | 8.4 | -2.7 | 3.8 | 4.7 | 4.7 | 5.2 | 5.8 | 6.2 | 6.6 |
| បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ | 9.8 | 11.5 | 12.0 | 9.0 | 9.0 | 8.0 | 7.5 | 7.5 | 7.5 |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 7.9 | 4.3 | 3.2 | -1.0 | -4.0 | 0.1 | 1.5 | 2.8 | 4.2 |
| អចលនទ្រព្យ | 8.7 | -8.3 | -8.5 | 0.5 | 0.0 | 1.2 | 2.8 | 3.7 | 4.9 |
| **អតិផរណា** | 1.8 | 2.9 | 2.9 | 5.3 | 2.1 | 2.7 | 2.5 | 2.5 | 2.5 |
| **អត្រាប្តូរប្រាក់** | 4,052 | 4,077 | 4,068 | 4,087 | 4,110 | 4,083 | 4 069 | 4 056 | 4 054 |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១៩-២០២២) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៣-២០២៧)*

**ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ)** ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ជាមធ្យមប្រមាណ -៣,៧% ដោយសារការរំពឹងទុកពីការរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ក៏នៅបន្តមាននិន្នាការល្អ ។ ការនាំចេញ រំពឹងថានឹងបន្តកើន ដែលបន្តជំរុញដោយការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ និងផលិតផលកសិកម្ម ។ ជាមួយគ្នានេះ, ការនាំចូល ក៏រំពឹងថានឹងបន្តនិន្នាការល្អ ដោយការកើននូវការនាំចូលវត្ថុធាតុដើមផលិតបម្រើឱ្យវិស័យកម្មន្តសាល និងផលិតកម្មផ្សេងៗក្នុងស្រុក, និងការនាំចូលទំនិញប្រើប្រាស់ផ្សេងៗ ដោយសារការបន្តកើននូវសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ។ លំហូរការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានព្យាករថានឹងបន្តកើន ក្នុងរង្វង់ជាមធ្យម ប្រមាណ **៨,៦% នៃ ផ.ស.ស.** ដោយសារការ-បន្តកើននូវទំនុកចិត្តវិនិយោគ ជាមួយនឹងបរិយាកាសកាន់តែអំណោយផលសម្រាប់ការវិនិយោគនៅកម្ពុជា តាមរយៈការអនុវត្ត **«ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា»** និងគោលនយោបាយគាំទ្រមួយចំនួនទៀត ។ គួរបញ្ជាក់ថា, ក្នុងរយៈពេលមធ្យមខាងមុខ, កម្ពុជារំពឹងថានឹងអាចទាក់ទាញវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់, ជាពិសេសក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ រួមមាន៖ បង្គុំអេឡិចត្រូនិក, ដំឡើងយានយន្ត, សូឡា, ផលិត-

កម្មសំបកកង់យានយន្ត និងផលិតផលកែច្នៃផ្សេងទៀត ។ ជាលទ្ធផល, ទុនបម្រុងអន្តរជាតិ នឹងបន្តកើន ដោយមានទំហំជាមធ្យមប្រមាណ **៧ ខែ** នៃការនាំចូល ។

## តារាងទី ៣៖ ទស្សនវិស័យនៃស្ថានភាពវិស័យខាងក្រៅកម្ពុជា ២០១៩-២០២៧

| សូចនាករ | 2019 | 2020 | 2021 | 2022 | 2023ប. | 2024ព្យ. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|---|---|---|---|
| ការនាំចេញ (លានដុល្លារអាម៉េរិក) | 14,986 | 18,522 | 19,521 | 23,179 | 23,564 | 25,845 | 29,385 | 33,226 | 37,569 |
| ការនាំចូល (លានដុល្លារអាម៉េរិក) | 22,242 | 21,066 | 30,726 | 32,005 | 26,551 | 30,467 | 35,506 | 40,816 | 46,457 |
| ឱនភាពសមតុល្យពាណិជ្ជកម្ម (លានដុល្លារអាម៉េរិក) | -7,255 | -2,544 | -11,257 | -8,826 | -2,986 | -4,622 | -6,122 | -7,590 | -8,888 |
| ឱនភាពគណនីចរន្ត (លានដុល្លារអាម៉េរិក) | -2,931 | -881 | -10,893 | -7,582 | 553 | -722 | -1,336 | -2,149 | -2,957 |
| លំហូរវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាម៉េរិក) | 3,663 | 3,625 | 3,486 | 3,579 | 3,959 | 4,250 | 4,556 | 4,871 | 5,194 |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាម៉េរិក) | 18,763 | 21,334 | 20,265 | 17,805 | 19,998 | 22,303 | 24,423 | 26,604 | 28,576 |
| ការនាំចេញ (ភាគរយនៃ ផ.ស.ស.) | 40.8% | 53.0% | 52.7% | 57.7% | 54.7% | 55.0% | 57.2% | 59.0% | 60.9% |
| ការនាំចូល (ភាគរយនៃ ផ.ស.ស.) | 60.5% | 60.3% | 82.9% | 79.7% | 61.6% | 64.8% | 69.1% | 72.5% | 75.3% |
| ឱនភាពសមតុល្យពាណិជ្ជកម្ម (ភាគរយនៃ ផ.ស.ស.) | -19.7% | -7.3% | -30.4% | -22.0% | -6.9% | -9.8% | -11.9% | -13.5% | -14.4% |
| ឱនភាពគណនីចរន្ត (ភាគរយនៃ ផ.ស.ស.) | -8.0% | -2.5% | -29.4% | -18.9% | 1.3% | -1.5% | -2.6% | -3.8% | -4.8% |
| លំហូរវិនិយោគផ្ទាល់ពីបរទេស (ភាគរយនៃ ផ.ស.ស.) | 10.0% | 10.4% | 9.4% | 8.9% | 9.2% | 9.0% | 8.9% | 8.6% | 8.4% |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | 8.8 | 13.4 | 7.4 | 6.1 | 8.2 | 8.0 | 7.5 | 7.2 | 6.8 |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា (២០១៩-២០២២) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៣-២០២៧)

## គ. ហានិភ័យ និងទិសដៅគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ដោយកម្ពុជា ជាប្រទេសដែលមានសេដ្ឋកិច្ចតូចហើយបើកចំហ (Small Open Economy) និងមានការផ្សារភ្ជាប់កាន់តែខ្លាំងជាមួយច្រវាក់ផលិតកម្មក្នុងតំបន់ និងពិភពលោក, ភាពមិនប្រាកដប្រជាពីកត្តាខាងក្រៅអាចនឹងប៉ះពាល់ជាអវិជ្ជមានមកលើសេដ្ឋកិច្ចដោយផ្ទាល់ និងប្រយោល ។ ក្នុងន័យនេះ, សម្រាប់រយៈពេលមធ្យមខាងមុខ, សេដ្ឋកិច្ចកម្ពុជា អាចនឹងជួបប្រទះនឹងហានិភ័យ និងភាពមិនប្រាកដប្រជាមួយចំនួន រួមមាន៖

១). កំណើនថមថយនៃសេដ្ឋកិច្ចសកល និងចិន;

២). ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល;

៣). ភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ចដែលអាចបន្ទប់បង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកល និងនាំទៅដល់ការកើនថ្លៃទំនិញជាអន្តរជាតិ;

៤). ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម; និង

៥). ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។

ទន្ទឹមនឹងការកើននៃហានិភ័យខាងក្រៅ, កម្ពុជា ក៏នៅតែបន្តប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធមួយចំនួនរួមមាន៖

១). ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច;
២). ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់;
៣). ភាពមានកម្រិតនៃកិច្ចសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច;
៤). បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ;
៥). ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម; និង
៦). ភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល ។

ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញការកែទម្រង់ជារចនាសម្ព័ន្ធ និងជាប្រព័ន្ធ ព្រមទាំងពង្រឹងការកសាងភាពធន់នៃសេដ្ឋកិច្ច និងសង្គម ឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់ ដោយផ្តោតលើអាទិភាពចំនួន ៦ ដូចមានចែងក្នុង **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»** រួមមាន ៖

- **ការអភិវឌ្ឍមូលធនមនុស្ស** តាមរយៈការពង្រឹងគុណភាពវិស័យអប់រំ, កីឡា, វិទ្យាសាស្ត្រ, និងបច្ចេកវិទ្យា; ការបណ្តុះបណ្តាលជំនាញបច្ចេកទេស; ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន; ការពង្រឹងប្រព័ន្ធគាំពារសង្គម; និងការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសមធម៌ និងបរិយាប័ន្ន ។
- **ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង** តាមរយៈការអភិវឌ្ឍវិស័យនៃប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ; ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និង វិស័យឌីជីថល; ការកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ; ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស, សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរី; និងការធ្វើនវានុវត្តន៍យន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ ។
- **ការអភិវឌ្ឍវិស័យឯកជន និងការងារ** តាមរយៈការអភិវឌ្ឍទីផ្សារការងារ; ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាពនិងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ; ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន; ការពង្រឹងការប្រកួតប្រជែងនិងយន្តការសេដ្ឋកិច្ចទីផ្សារឱ្យកាន់តែមានប្រសិទ្ធភាព; និងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុធនាគារ និងមិនមែនធនាគារ ។
- **ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និង បរិយាប័ន្ន** តាមរយៈការធ្វើអតិបរមានីយកម្មផលលាភប្រជាសាស្ត្រ; ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ; ការគ្រប់គ្រងធនធានធម្មជាតិ, វប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព; ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ; ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម; និងការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង ។
- **ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល** តាមរយៈការកសាងរដ្ឋាភិបាល និងពលរដ្ឋឌីជីថល; ការអភិវឌ្ឍធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, និងប្រព័ន្ធនវានុវត្តន៍ឌីជីថល; ការកសាង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល; ការកសាងភាពជឿជាក់លើប្រព័ន្ធឌីជីថល; និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ។

- **ការបន្តពង្រឹងរដ្ឋបាលសាធារណៈ** តាមរយៈការបន្តកែទម្រង់ស្ថាប័នរដ្ឋ ដោយផ្តោតលើការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពក្នុងការអនុវត្តការងារ; ការសម្រិតសម្រាំងមន្ត្រីមានសមត្ថភាពខ្ពស់ និងគុណវុឌ្ឍិល្អ ឱ្យទទួលខុសត្រូវការងារសំខាន់ៗ; ព្រមទាំងការលើកកម្ពស់ការទទួលខុសត្រូវ និងភាព-ជាម្ចាស់ការរបស់ក្រសួង-ស្ថាប័ន ដើម្បីឈានទៅសម្រេចបានរដ្ឋបាលសាធារណៈ ដែលស្អាតស្អំ, ឆ្លាតវៃ និងមានសមត្ថភាពខ្ពស់ ។

## ៣. យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ

**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧** ដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដោយកំណត់នូវ **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** (Fiscal Policy Stance), **វិធានហិរញ្ញវត្ថុសាធារណៈ** (Fiscal Rules) និង **អាទិភាពគោលនយោបាយ** (Policy Priorities) ដោយសំដៅធានានូវការសម្រេចឱ្យបាននូវគោលបំណងសំខាន់ៗ ៣ រួមមាន៖ (១)-គាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល; (២)-ពង្រឹងប្រសិទ្ធភាពនៃការវិភាជថវិកា; និង (៣)-ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ។

### ៣.១. ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាកាន់តែខ្ពស់, **គោលនយោបាយហិរញ្ញវត្ថុសាធារណៈ**សម្រាប់រយៈពេលមធ្យមខាងមុខ នឹងត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវ «**ជំហរគោលនយោបាយពង្រឹងប្រសិទ្ធ-ភាពថវិកាជាជំហាន** (Gradual Fiscal Consolidation Stance)» ។ ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម តាមរយៈការចាប់ផ្តើមកសាងទ្រនាប់ថវិកាឡើងវិញ ក្រោយពីបានដាក់ចេញវិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ ២០២០ មក, រាជរដ្ឋាភិបាល នឹងផ្តោតជាសំខាន់លើការបន្តពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ, តាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយដោយតម្រង់ទិសធនធានទៅកាន់មុខសញ្ញា ដែលជាអាទិភាពសំខាន់ៗចំពោះមុខ ពោលគឺចាយវាយឱ្យចំទិសដៅ ហើយផ្តោតលើតម្លៃនៃលុយ, ខណៈពង្រឹងការប្រមូលចំណូលឱ្យបានកាន់តែប្រសើរ ដោយត្រូវមានការថ្លឹងថ្លែងជាមួយនឹងការបន្តរក្សាឱ្យបាននូវចលនការ និងសន្ទុះនៃសកម្មភាពសេដ្ឋកិច្ច ដោយខិតខំចៀសវាងឱ្យបានជាអតិបរមានូវវិការភាពសេដ្ឋកិច្ច (Economic Distortion) ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលនឹងដាក់ចេញនូវវិធាន-ការពន្ធ ដែលមានការកែទម្រង់ស៊ីជម្រៅទៅលើផ្នែករដ្ឋបាល និងទំនើបភាវូបនីយកម្មពន្ធ ក្រោមអភិក្រមមិនបង្កើតបន្ទុកពន្ធថ្មី ដោយថ្លឹងថ្លែងការរក្សាបាននូវចលនការសេដ្ឋកិច្ច និងការបន្តបង្កើនចំណូលសម្រាប់តម្រូវការអភិ-វឌ្ឍន៍ជាតិ ។ ចំណែកឯការកសាងទ្រនាប់ថវិកា នឹងធ្វើឡើងដោយផ្អែកទៅតាមលទ្ធភាពនៃវឌ្ឍនភាពក្នុងការកៀរ-គរចំណូល និងការធ្វើវិចារណកម្ម និងការបង្កើនប្រសិទ្ធភាពចំណាយ ។

ជាមួយនឹងការអនុវត្ត «**ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន**» នេះ, ឱនភាពថវិកាក្នុងរយៈពេលមធ្យម នឹងចាប់ផ្តើមរួមតូច និងជាសន្សឹមៗ ។ ក្នុងនោះ, ចំពោះផ្នែកចំណូល, រាជរដ្ឋាភិបាលនឹងពង្រីកមូលដ្ឋានចំណូល ប្រកបដោយភាពហ្មត់ចត់ និងទន់ភ្លន់ខ្ពស់ ព្រមទាំងបន្តអនុវត្តវិធានការលើកទឹកចិត្តនានារបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ជវភាពកំណើនសេដ្ឋកិច្ច ។រីឯផ្នែកចំណាយ នឹងត្រូវបានពង្រឹងប្រសិទ្ធភាពប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាឱ្យបាននូវលទ្ធភាពក្នុងការទ្រទ្រង់ចលនការអភិវឌ្ឍន៍សេដ្ឋកិច្ច

ព្រមទាំងធានាពុំឱ្យមានការបន្ទច់បង្អាក់ដល់និរន្តរភាពប្រតិបត្តិការការងាររបស់រាជរដ្ឋាភិបាល និងការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ស្របតាមទិសដៅជាយុទ្ធសាស្ត្រដែលបានដាក់ចេញនៅក្នុង «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» ។

## ៣.២. វិធានហិរញ្ញវត្ថុសាធារណៈ

**វិធានហិរញ្ញវត្ថុសាធារណៈ** គឺជាផ្នែកមួយដ៏សំខាន់ ក្នុងការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈ-ពេលមធ្យម ត្រូវបានបែងចែកជា ២ គឺ ៖ ១). **យុថ្កាហិរញ្ញវត្ថុសាធារណៈ** (Fiscal Anchor) ដែលជាវិធានសម្រាប់រយៈពេលមធ្យម និង ២). **វិធានប្រតិបត្តិ** (Operational Rules) ដែលជាវិធានប្រចាំឆ្នាំ ។ ការកំណត់នូវវិធានហិរញ្ញវត្ថុសាធារណៈត្រូវបានធ្វើឡើង ដើម្បីដាក់ចេញនូវលក្ខខណ្ឌជាក់លាក់លើសូចនាករសំខាន់ៗនៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ, លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំក្របខ័ណ្ឌថវិកា, ពង្រឹងប្រសិទ្ធភាព និងវិន័យក្នុងការអនុវត្តថវិកា, និងជាពិសេស ធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈ ។

### ក. យុថ្កាហិរញ្ញវត្ថុសាធារណៈ

**យុថ្កាហិរញ្ញវត្ថុសាធារណៈ** គឺជា វិធានហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម សម្រាប់តម្រង់ទិសនៃការរៀបចំក្របខ័ណ្ឌថវិកា ឱ្យដើរស្របតាមលទ្ធភាពរបស់ប្រទេសក្នុងការទ្រទ្រង់បំណុល និងធានាឱ្យខាងតែបានមិនឱ្យបំណុលជាតិធ្លាក់ខ្លួនចូលក្នុងកម្រិតហានិភ័យ ។ ក្នុងន័យនេះ, **យុថ្កាហិរញ្ញវត្ថុសាធារណៈ** ត្រូវបានកំណត់ឡើង ដោយផ្អែកលើលទ្ធផលនៃការវិភាគចីរភាពបំណុលសាធារណៈ (Debt Sustainability Analysis – DSA) ដែលនឹងរួមចំណែក ៖ ១). ធានានូវឱនភាពថវិកាឱ្យស្ថិតនៅក្នុងកម្រិតសមស្រប, ២). ធានាសាធនភាពហិរញ្ញ-វត្ថុសាធារណៈ (Fiscal Solvency), និង ៣). គ្រប់គ្រងហានិភ័យសន្ទនីយភាពក្នុងរយៈពេលខ្លី (Liquidity Risk) ។

សម្រាប់រយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧, **យុថ្កាហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា** ត្រូវបានកំណត់ជាពិតានលើសូចនាករពាក់ព័ន្ធនឹងផ្នែកសាធនភាព និងសន្ទនីយភាព សរុប **៥ សូចនាករគន្លឹះ** រួមមាន៖

(១). **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស.** ត្រឹមកម្រិត **៥៥%**;
(២). **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស.** ត្រឹមកម្រិត ៤០%;
(៣). **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ** ត្រឹមកម្រិត ១៨០%;
(៤). **អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ** ត្រឹមកម្រិត **១៥%**; និង
(៥). **អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិ** ត្រឹមកម្រិត **១៨%** ។

### ខ. វិធានប្រតិបត្តិ

**វិធានប្រតិបត្តិ** គឺជាវិធានហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ ដែលកំណត់លក្ខខណ្ឌជាក់លាក់លើសូចនាករសំខាន់ៗ ក្នុងការរៀបចំក្របខ័ណ្ឌថវិកាប្រចាំឆ្នាំ ដូចជា ចំណូល, ចំណាយ ឬ តុល្យភាពថវិកា ហើយផ្សារភ្ជាប់នឹងការអនុវត្តថវិកា ដោយគោរពតាមយុថ្កាហិរញ្ញវត្ថុសាធារណៈដែលបានដាក់ចេញ ។ ជាទូទៅ, **វិធានប្រតិបត្តិ** ដែលដាក់ចេញក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម អាចមានមួយ ឬ ច្រើន ទៅតាមបរិការណ៍សេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ក្នុងប្រទេសនីមួយៗ ។ ជាមួយគ្នា, ការដាក់ចេញនូវវិធាននេះត្រូវមានការគិតគូរ ផ្អែកលើគោលការណ៍សំខាន់ៗមួយចំនួន រួមមាន ៖ ការចូលរួមធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច (Stabilization), សាមញ្ញភាពក្នុងការរៀបចំ និងអនុវត្តថវិកា (Simplicity), ភាពជឿទុកចិត្តបាននៃវិធានដែលបាន

ដាក់ចេញ (Credibility) ព្រមទាំងភាពងាយស្រួល ក្នុងការតាមដាន និងក្នុងការអនុវត្ត (Ease of Monitoring and Enforcement) ។

សម្រាប់កម្ពុជា ដែលជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប, **ការកំណត់វិធានប្រតិបត្តិដោយប្រើវិធានតុល្យភាពថវិកា (Budget Balance Rule)** មានលក្ខណៈសមស្របបំផុត ដោយសារសេដ្ឋកិច្ចកម្ពុជា គឺជាសេដ្ឋកិច្ចកំពុងរីកលូតលាស់ និងស្របតាមរបត់នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលនៅមានតម្រូវការនៃការវិនិយោគសាធារណៈខ្ពស់ ។ ទន្ទឹមនេះ, ការកំណត់វិធានតុល្យភាពថវិកា ក៏ជាឧត្តមានុវត្តន៍ និងត្រូវបានអនុវត្តនៅតាមបណ្តាប្រទេសភាគច្រើនផងដែរ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលកំណត់យកពិតានតុល្យភាពថវិកាសរុបប្រចាំឆ្នាំ ជាវិធានប្រតិបត្តិ ដោយកំណត់ **ឱនភាពថវិកាសរុប មិនត្រូវលើសពីកម្រិត -៥,០% នៃ ផ.ស.ស.** សម្រាប់ការរៀបចំ **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧»** ។

ការកំណត់កម្រិតឱនភាពថវិកានេះ ធ្វើឡើងក្នុងន័យបន្តរក្សាចីរភាពបំណុលសាធារណៈ និងធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ស្របតាមជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកា, ខណៈនៅតែផ្តល់លទ្ធភាពសម្រាប់ការអនុវត្តគោលនយោបាយអាទិភាព សំដៅរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគាំទ្រការស្តារ និងការជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ។ ឈរលើមូលដ្ឋាននៃការបន្តរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការគ្រប់គ្រងឱនភាពថវិកា ដោយអនុលោមឱ្យបានតាមវិធានប្រតិបត្តិនេះ ក៏នឹងធានាឱ្យកម្រិតបំណុលសាធារណៈកម្ពុជាបន្តរក្សាបាននូវចីរភាព និងស្ថិតក្នុងកម្រិតហានិភ័យទាបផងដែរ ។ **ទោះជាយ៉ាងនេះក្តី, ក្នុងករណីប្រធានសក្តិ ដូចជា គ្រោះធម្មជាតិ, ការរីករាលដាលនៃជំងឺឆ្លងជាសកល, គ្រោះអាសន្នថ្នាក់ជាតិ, ឬ ភាពចាំបាច់ជាបន្ទាន់សម្រាប់ប្រយោជន៍ជាតិ ដែលបង្កឱ្យមានការប្រែប្រួលខ្លាំងដល់សម្មតិកម្មម៉ាក្រូសេដ្ឋកិច្ច និងមូលដ្ឋាននៃការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, ការអនុវត្តវិធានប្រតិបត្តិអាចមានភាពទន់ភ្លន់ជាងការកំណត់នេះ ដើម្បីផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់រាជរដ្ឋាភិបាលក្នុងការធ្វើអន្តរាគមន៍ និងដោះស្រាយបញ្ហាប្រឈមបានទាន់ពេល ។**

## ៣.៣. អាទិភាពគោលនយោបាយ

ដើម្បីធានាការសម្រេចបាននូវទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ស្របតាមទិសដៅគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដែលត្រូវបានដាក់ចេញក្នុង **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** និង **«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការការពារមាតុភូមិ ឆ្នាំ ២០២៣-២០២៨»**, **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧»** កំណត់យកអាទិភាពគោលនយោបាយសំខាន់ៗ ដូចខាងក្រោម ៖

- បន្តការពារសន្តិភាព, ស្ថិរភាពនយោបាយ, សមិទ្ធផលសង្គម និងជំរុញការដោះស្រាយបញ្ហាគ្រោះអាសន្ននានា ក្នុងសង្គម ដើម្បីរក្សាសុវត្ថិភាព និងសុខដុមរមនាប្រជាជន;
- បន្តថែរក្សាសមិទ្ធផលគោលនយោបាយការបរទេស ដោយបន្តអនុវត្តនយោបាយឯករាជ្យ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងពិភពលោក;
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងគាំទ្រដល់វិស័យគន្លឹះដែលមានស្រាប់ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម ប្រកបដោយចីរភាព, បរិយាប័ន្ន និងភាពធន់;
- ជំរុញការអភិវឌ្ឍមូលធនមនុស្ស ដោយការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីគាំទ្រផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់;

- លើកកម្ពស់ភាពជាពលរដ្ឋក្នុងសង្គម លើកកម្ពស់វប្បធម៌ និងសុខុមាលភាពប្រជាជន សម្រាប់ការត្រៀមខ្លួនជាប្រជាជននៃប្រទេសចំណូលមធ្យមកម្រិតខ្ពស់;
- បន្តជំរុញពិពិធកម្មសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍវិស័យដែលជាប្រភពថ្មីនៃកំណើន គាំទ្រដល់បរិយាកាសប្រកួតប្រជែង និងការអនុវត្តយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ ដែលបង្កើនតម្លៃបន្ថែមខ្ពស់;
- កសាងជាជំហានៗឆ្ពោះទៅ ការគ្របដណ្តប់សុខភាពជាសកល តាមរយៈការពង្រឹងប្រព័ន្ធសុខាភិបាលជារួម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា និងបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ, និងបន្តអភិវឌ្ឍប្រព័ន្ធស្បៀង ដែលផ្តល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ប្រជាជនគ្រប់រូប;
- បន្តជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទ, ទាំងរឹង និង ទន់, ដើម្បីបង្កើនផលិតភាព, លើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញពិពិធកម្ម;
- បន្តជំរុញការធ្វើបរិវត្តកម្មឌីជីថល ដោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង ដើម្បីកសាងរដ្ឋាភិបាល និងពលរដ្ឋឌីជីថលប្រកបដោយចីរភាព;
- បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌; និង
- បន្តលើកស្ទួយវិស័យឯកជន ដោយគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, សេដ្ឋកិច្ចក្រៅប្រព័ន្ធដោយមានការបង្កើតបរិយាកាសល្អប្រសើរ តាមរយៈការពង្រឹងការអនុវត្តច្បាប់វិនិយោគថ្មី, ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ចជាមួយនឹងភាពប្រកួតប្រជែង និងសមភាព ។

# ៤. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

## ៤.១. ការអនុវត្តថវិកា ឆ្នាំ ២០២៣ និង ២០២៤

### ក. ការអនុវត្តថវិកា ឆ្នាំ ២០២៣

សម្រាប់ឆ្នាំ ២០២៣, **លទ្ធផលនៃការប្រមូលចំណូលក្នុងស្រុក** (តួលេខបណ្តោះអាសន្ន) សម្រេចបានប្រមាណ ១៥,៣៥% នៃ ផ.ស.ស. ពោលគឺមានការថមថយប្រមាណ -១,៥% ធៀបនឹងលទ្ធផលឆ្នាំ ២០២២ ។ ការថយចុះនេះ ដោយសារការប្រមូលចំណូលពីវិស័យដែលជាចន្ទល់កំណើនសេដ្ឋកិច្ចជាតិឆ្នាំ ២០២៣ រួមមានវិស័យកសិកម្ម, កម្មន្តសាលមិនមែនកាត់ដេរ និងទេសចរណ៍ នៅមានទំហំតិចតួចនៅឡើយ, ខណៈមូលដ្ឋានចំណូលសំខាន់ៗ ត្រូវរងការប៉ះទង្គិចខ្លាំងដោយសារការធ្លាក់ចំណូលគួរឱ្យកត់សម្គាល់ពីការនាំចូលយានយន្ត និងនិន្នាការកើនយឺតនៃលទ្ធផលចំណូលពន្ធប្រមូលប្រចាំខែពីសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ទន្ទឹមនឹងការបន្តដាក់ឱ្យអនុវត្តនូវវិធានការលើកទឹកចិត្តដែលមានស្រាប់នានា និងការពង្រីកនូវវិសាលភាពក្នុងការលើកលែង ឬ បន្ធូរបន្ថយការបង់ពន្ធ ដើម្បីសម្រួលដល់បរិយាកាសធុរកិច្ច, ជំរុញការវិនិយោគក្នុងស្រុក និងទ្រទ្រង់ចលនការនៃការងើបឡើងវិញនៃសេដ្ឋកិច្ច ។

ចំពោះមុខនៃការធ្លាក់ចំណូលនេះ, **ការអនុវត្តចំណាយក្នុងឆ្នាំ ២០២៣** ត្រូវបានប៉ាន់ស្មានថាអនុវត្តបានត្រឹមក្នុងទំហំប្រមាណ ២០,៥០% នៃ ផ.ស.ស. (តួលេខបណ្តោះអាសន្ន) ទាបជាងការគ្រោងក្នុងច្បាប់ ពោល

គឺស្មើនឹងប្រមាណ ៩២,៦% នៃច្បាប់ថវិកា ។ ទោះជាយ៉ាងនេះក្តី, រាជរដ្ឋាភិបាល នៅតែមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តកម្មវិធីគោលនយោបាយសំខាន់ៗ ដែលបានដាក់ចេញក្នុងឆ្នាំ ដូចជាការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បំពាក់គុណវុឌ្ឍិវិជ្ជាជីវៈជំនាញ, បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងលើកកម្ពស់សមត្ថភាពមន្ត្រី, ជាពិសេស គាំទ្រដល់ការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពនានា ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលបានអនុវត្តនូវកម្មវិធីអន្តរាគមន៍សង្គម-សេដ្ឋកិច្ច ដែលអនុវត្តថវិកាអស់ប្រមាណ ៧៥៤ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់កម្មវិធីសំខាន់ៗ រួមមាន កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ (ក្រ១, ក្រ២), កម្មវិធីឧបត្ថម្ភសាច់ប្រាក់មួយគ្រាជូនគ្រួសារងាយរងគ្រោះ, កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ, ហិរញ្ញប្បទានគាំទ្រយុទ្ធសាស្ត្រនិងកម្មវិធីស្តារ និងជំរុញកំណើន និងគម្រោងអភិវឌ្ឍន៍តំបន់រុនតាឯក និងតំបន់ពាក់ស្នែង ។

ជាលទ្ធផល, **ឱនភាពថវិកាឆ្នាំ ២០២៣** ត្រូវបានប៉ាន់ស្មានក្នុងរង្វង់ -៥,១៥% នៃ ផ.ស.ស. ទាបជាងច្បាប់ថវិកាប្រមាណ ០,៤៤ ពិន្ទុភាគរយ ឆ្លុះបញ្ចាំងអំពីស្មារតីប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាលក្នុងការធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ។ ទោះជាយ៉ាងនេះក្តី, គ្រប់អនុបាតបំណុលសាធារណៈរបស់កម្ពុជា គឺសុទ្ធស្ថិតក្រោមអនុបាតគោលទាំងអស់ ដែលប្រការនេះបញ្ជាក់ថា ស្ថានភាពបំណុលសាធារណៈកម្ពុជា នៅតែបន្តមានចីរភាព និងហានិភ័យកម្រិតទាប ។

## ខ. ការប៉ាន់ស្មានការអនុវត្តថវិកាឆ្នាំ ២០២៤

ក្នុងឆ្នាំ ២០២៤ នេះ, រាជរដ្ឋាភិបាលបានប្រកាន់ជំហាននៃការអនុវត្ត **«គោលជំហរពង្រឹងប្រសិទ្ធភាពថវិកា»** សំដៅជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ក្នុងបរិការណ៍នៃការបន្តកសាងទ្រនាប់ថវិកាឱ្យមានភាពធន់ និងរឹងមាំ សំដៅលើកកម្ពស់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ក្នុងនោះ, ចំណូលចរន្តក្នុងឆ្នាំ ២០២៤ ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានកំណើនយឺត ពោលគឺក្នុងអត្រា ៤,៤% ធៀបនឹងលទ្ធផលអនុវត្ត (បណ្តោះអាសន្ន) ឆ្នាំ ២០២៣ សមមូលនឹងត្រឹមប្រមាណ ១៤,៦២% នៃ ផ.ស.ស. និង ៨៩,៧% នៃច្បាប់ថវិកា ។ ក្នុងស្ថានភាពនេះ, រាជរដ្ឋាភិបាលនៅតែបន្តកិច្ចខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំក្នុងការពង្រឹងរដ្ឋបាលសារពើពន្ធសំដៅជួយឱ្យចំណូល ជារួម បន្តមានកំណើន, ជាពិសេសតាមរយៈការអនុវត្តគោលនយោបាយគាំទ្រនានា ដែលនឹងជួយជំរុញបន្ថែមទៀតនូវសកម្មភាពធុរកិច្ច និងពាណិជ្ជកម្មក្នុងស្រុក ឱ្យកាន់តែមានភាពមមាញឹក និងធន់នឹងវិបត្តិ ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល បាននិងកំពុងបន្តធ្វើការកៀរគរប្រភពហិរញ្ញប្បទានដែលមានសក្តានុពលនៅលើទីផ្សារក្នុងស្រុកបន្ថែមផងដែរ តាមរយៈការបន្តបោះផ្សាយមូលបត្ររដ្ឋក្នុងឆ្នាំ ២០២៤ បន្ថែមក្នុងទំហំប្រមាណ ៤៤០ ប៊ីលានរៀល សំដៅបង្កើនធនធានថវិកាសម្រាប់ការវិនិយោគសាធារណៈ និងការវិនិយោគទៅលើប្រភពថ្មីនៃកំណើនដែលមានសក្តានុពលសេដ្ឋកិច្ច និងផ្តល់ផលរហ័ស ។

ក្នុងស្ថានភាពចំណូលខាងលើ, ចំណាយសរុបឆ្នាំ ២០២៤ ត្រូវបានប៉ាន់ស្មានថានឹងមានទំហំប្រមាណ ១៨,៤០% នៃ ផ.ស.ស. សមមូលនឹងប្រមាណ ៩៥,២% នៃច្បាប់ ដែលក្នុងក្របខ័ណ្ឌចំណាយនេះ រាជរដ្ឋាភិបាល បានគិតគូរយ៉ាងហ្មត់ចត់លើអាទិភាពចំណាយ ដើម្បីបន្តពង្រឹងសមត្ថភាព និងប្រតិបត្តិការសំខាន់ៗរបស់ស្ថាប័ន, លើកកម្ពស់សមត្ថភាពមន្ត្រី និងបំពាក់បំប៉នគុណវុឌ្ឍិវិជ្ជាជីវៈជំនាញ ស្របតាមតម្រូវការចាំបាច់ ។ ជាលទ្ធផល, ឱនភាពថវិកា ឆ្នាំ ២០២៤ ត្រូវបានប៉ាន់ស្មានថានឹងស្ថិត ក្នុងរង្វង់ប្រមាណ -៣,១៥% នៃ ផ.ស.ស. ។

ក្នុងនោះ, **តម្លៃបច្ចុប្បន្ននៃសន្និធិបំណុលសាធារណៈសរុបរបស់កម្ពុជា** ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនទាបក្នុងអត្រាប្រមាណ ១៩,៣០% នៃ ផ.ស.ស. ដែលអនុបាតនេះ, រួមទាំងអនុបាត ៤ ផ្សេងទៀត, នៅតែបន្តស្ថិតនៅក្រោមអនុបាតគោល ។

**តារាងទី ៤៖ សូចនាករវិធានហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២១-២០២៤**

| សូចនាករ | អនុបាតគោល | 2021 | 2022 | 2023ប. | 2024ប៉ាន់. |
|---|---|---|---|---|---|
| I. យុទ្ធាហិរញ្ញវត្ថុសាធារណៈ | | | | | |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | 55% | 18.64% | 18.07% | 18.81% | 19.30% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. | 40% | 18.64% | 18.03% | 18.69% | 19.02% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | 180% | 34.24% | 28.38% | 29.00% | 29.09% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | 15% | 1.90% | 1.82% | 1.78% | 1.81% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ | 18% | 5.33% | 5.44% | 5.83% | 7.76% |
| II. វិធានប្រតិបត្តិ | | | | | |
| ឱនភាពថវិកាសរុប | -5% | -7.53% | -2.93% | -5.15% | -3.15% |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ៤.២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៥-២០២៧

«**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧**» ត្រូវបានរៀបចំឡើងយ៉ាងហ្មត់ចត់ និងមានការថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយ រវាងធនធានដែលមាន និងតម្រូវការចំណាយ ដោយផ្ដោតលើទិដ្ឋភាពចំនួន ៣ ធំៗ រួមមាន ៖ ១). លទ្ធភាពក្នុងការបង្កើនការប្រមូលចំណូលក្នុងរយៈពេលមធ្យម នៅមានភាពមិនប្រាកដប្រជាខ្ពស់នៅឡើយ ស្របគ្នាទៅនឹងការប្រកាន់គោលជំហរពុំបង្កើនបន្ទុកពន្ធថ្មី; ២). តម្រូវការថវិកាសម្រាប់បន្តការងារកែទម្រង់ និងពង្រឹងសមត្ថភាពស្ថាប័ន, បន្តការអនុវត្តកម្មវិធីគាំពារសង្គម និងអភិវឌ្ឍន៍មូលធនមនុស្ស ព្រមទាំងការអនុវត្តគោលនយោបាយអាទិភាព និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងមានភាពធន់ សម្រាប់កិច្ចអភិវឌ្ឍ; និង ៣). ស្ថានភាពលម្ហថវិកាបច្ចុប្បន្ន ដែលកំពុងមានការ-រួមតូច ដោយសារម្ខាង, លទ្ធផលប្រមូលចំណូលក្នុងឆ្នាំ ២០២៣ ពុំសម្រេចបានដូចការគ្រោង, និងម្ខាងទៀត, ដោយសារការអនុវត្តគោលនយោបាយវិត្តារកម្មថវិកា ដើម្បីឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិបន្តបន្ទាប់ ។ ការណ៍នេះទាមទារ ឱ្យរាជរដ្ឋាភិបាលត្រូវមានការគិតគូរធ្វើអាទិភាវូបនីយកម្មមុខចំណាយ ដើម្បីធានាបាននូវលម្ហថវិកាគ្រប់គ្រាន់ សម្រាប់បំពេញដល់តម្រូវការមុខសញ្ញាចំណាយចាំបាច់នានា ។ ក្នុងន័យនេះ, «**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម**» នឹងក្លាយជាឧបករណ៍ដ៏សំខាន់ សម្រាប់រាជរដ្ឋាភិបាល ក្នុងការអនុវត្តវិធានការគោលនយោបាយនានា ប្រកបដោយភាពម្ចាស់ការ, ប៉ុន្តែនៅតែរក្សាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅលើកកម្ពស់ការកសាងមូលដ្ឋានគ្រឹះសេដ្ឋកិច្ច ក៏ដូចជាពង្រឹង និងពង្រីកសសរស្ដម្ភសេដ្ឋកិច្ចជាតិឱ្យមានដរភាព, ភាពចម្រុះ, ភាពរឹងមាំ និងភាពធន់ ។

## ក. ក្របខ័ណ្ឌចំណូល

**ចំណូលសរុប ក្នុងឆ្នាំ ២០២៥ ត្រូវបានព្យាករថានឹងសម្រេចបានក្នុងទំហំប្រមាណ ១៥,១១% នៃ ផ.ស.ស. ដែលសមមូលនឹងកំណើនប្រមាណ ៧,៩% ។ ក្នុងនោះ, ចំណូលចរន្ត ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១៤,៥២% នៃ ផ.ស.ស., សមមូលនឹងអត្រាកំណើនក្នុងរង្វង់ ៨,២% ធៀបនឹងលទ្ធផលប៉ាន់-ស្មានក្នុងឆ្នាំ ២០២៤** ។ បន្ថែមលើនេះ, ចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានព្យាករថានឹងមានកំណើនប្រមាណ ៧,៣% និង ៧,៤% រៀងគ្នា, ខណៈចំណូលមិនមែនសារពើពន្ធ ត្រូវបានព្យាករថានឹងសម្រេចបានកំណើនប្រមាណ ១៤,៣% ធៀបនឹងលទ្ធផលប៉ាន់ស្មានក្នុង ឆ្នាំ ២០២៤ ។ ជារួម, លទ្ធផលព្យាករណ៍នេះ ផ្អែកចម្បងលើការរំពឹងទុកនៃការចាប់រើបឡើងវិញនូវកំណើនសេដ្ឋកិច្ចកម្ពុជា, ជាពិសេសសកម្មភាពធុរកិច្ចក្នុងស្រុក រួមទាំងបច្ច័យវិជ្ជមានពីការអនុវត្តគោលនយោបាយគាំទ្រនានា របស់រាជរដ្ឋាភិបាល ដែលនឹងជួយជំរុញបន្ថែមទៀតឱ្យសកម្មភាពធុរកិច្ចពាណិជ្ជកម្មក្នុងស្រុក កាន់តែមានភាពរស់-រវើក រួមជាមួយនឹងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរវិនិយោគិនពីបរទេស ។

### តារាងទី ៥៖ ការព្យាករចំណូលរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧

| | កំណើនប្រចាំឆ្នាំ | | | ភាគរយនៃ ផ.ស.ស. | | |
|---|---|---|---|---|---|---|
| | 2025ព្យ. | 2026ព្យ. | 2027ព្យ. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
| ចំណូលសរុប | 7.9% | 11.1% | 11.2% | 15.11% | 15.36% | 15.61% |
| ចំណូលចរន្ត | 8.2% | 11.8% | 11.7% | 14.52% | 14.85% | 15.15% |
| ចំណូលសារពើពន្ធ | 7.3% | 11.7% | 11.6% | 12.63% | 12.91% | 13.16% |
| អគ្គនាយកដ្ឋានពន្ធដារ | 7.3% | 12.8% | 12.6% | 7.78% | 8.03% | 8.26% |
| *ក្នុងនោះ៖ ថ្នាក់ក្រោមជាតិ* | 7.0% | 12.6% | 12.3% | 1.06% | 1.09% | 1.12% |
| អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | 7.4% | 9.8% | 10.0% | 4.85% | 4.88% | 4.90% |
| ចំណូលមិនមែនសារពើពន្ធ | 14.3% | 12.5% | 12.3% | 1.89% | 1.94% | 1.99% |
| *ក្នុងនោះ៖ ថ្នាក់ក្រោមជាតិ* | *5.3%* | *5.0%* | *5.7%* | 0.10% | 0.09% | 0.09% |
| ចំណូលផ្សេងៗ | *2.1%* | *-6.2%* | *-1.5%* | *0.59%* | *0.51%* | *0.46%* |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ចំណូលសរុប ក្នុងរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៧ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យមក្នុងអត្រា ១១,១% និងស្ថិតក្នុងទំហំ ១៥,៦១% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៧ ស្របតាមការបន្តរីកធំនៃមូលដ្ឋានចំណូល** ។ ក្នុងនោះ, ចំណូលចរន្ត ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ១១,៧% និងស្ថិតក្នុងរង្វង់ ១៥,១៥% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៧ ដែលក្នុងនោះ ចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានព្យាករថានឹងសម្រេចបានកំណើនជាមធ្យមក្នុងអត្រា ១២,៧%, ខណៈចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានរំពឹងថានឹងសម្រេចបានកំណើនយឺត ពោលគឺក្នុងរង្វង់ ៩,៩% ។ ជារួម, ចំណូលរបស់អគ្គនាយកដ្ឋានទាំង ២ ប្រឈមនឹងការកើននៃចំណាយបន្ទុកសារពើពន្ធ (Tax Expenditure) ពីការបន្តពង្រីកវិសាលភាពនៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការអនុគ្រោះផ្នែកសារពើពន្ធ អនុលោមតាមច្បាប់វិនិយោគ ឆ្នាំ ២០២១ ។ ជាមួយគ្នានេះ, ចំណូលមិនមែនសារពើពន្ធ ត្រូវបានរំពឹងថាសម្រេចបានកំណើនជា

មធ្យម ក្នុងរង្វង់ ១២,៤% និងស្ថិតក្នុងទំហំ ១,៩៩% នៃ ផ.ស.ស. ជាមួយនឹងការបន្តពង្រឹងការកៀរគរចំណូលពីប្រភពដែលនៅមានសក្តានុពល, ស្របពេលដែលចំណូលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ត្រូវបានរំពឹងទុកថានឹងបន្តស្ទុះឡើង ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមលើការប្រមូលចំណូល សំដៅទ្រទ្រង់ចលនការនៃចីរភាពកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ បាននិងកំពុងគិតគូរ រៀបចំ **ក្របខ័ណ្ឌយុទ្ធសាស្ត្រកៀរគរចំណូល** ដំណាក់កាលបន្ទាប់ (២០២៤-២០២៨) ក្នុងគោលដៅបន្តពង្រឹងការកៀរគរ និងគ្រប់គ្រងចំណូល រួមមានជាអាទិ៍ អនុវត្តក្របខ័ណ្ឌគោលនយោបាយសម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធប្រាក់ចំណូលរូបវន្តបុគ្គល, គោលការណ៍ស្តីពីអាករពិសេស និងការសិក្សាដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធសារពើពន្ធកម្ពុជា ដើម្បីបន្តអភិវឌ្ឍប្រព័ន្ធចំណូលរដ្ឋ ដែលអាចឆ្លើយតបបានទៅនឹងការវិវត្តនៃសង្គម-សេដ្ឋកិច្ច ព្រមទាំងធានាការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព, ភាពត្រឹមត្រូវ, យុត្តិធម៌ និងសមធម៌សង្គម ។

ក្នុងន័យនេះ, **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧»** ដាក់ចេញនូវវិធានការគន្លឹះលើផ្នែកចំណូលបន្ថែម ដូចខាងក្រោម៖

### ■ វិធានការផ្នែកពន្ធដារ

- បន្តពង្រឹងការធ្វើសមាហរណកម្ម និងការចែករំលែក និងការផ្លាស់ប្តូរព័ត៌មាន និងទិន្នន័យជាមួយភាគីទីបី (Third-party data integration) ជាអាទិ៍ក្រសួង-ស្ថាប័នពាក់ព័ន្ធស្ថាប័នហិរញ្ញវត្ថុ តាមរយៈថ្នាលឌីជីថល;
- ពង្រឹងប្រសិទ្ធភាព នៃយន្តការ ឬ ប្រព័ន្ធផ្តល់មតិយោបល់ (Feedback Mechanism) ពីអ្នកជាប់ពន្ធដែលអាចធានាបាននូវភាពសម្ងាត់នៃឯកជនភាព, ទំនុកចិត្តខ្ពស់ និងឆ្លើយតបដល់អ្នកជាប់ពន្ធ;
- កែសម្រួលកម្រិតជាប់ពន្ធក្នុងតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពាក់ព័ន្ធនឹងអចលនទ្រព្យ ដោយធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ, ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពង្រឹងការបង់ពន្ធប្រថាប់ត្រា;
- ចូលរួមអនុវត្តវិធានការពាក់ព័ន្ធនឹងពន្ធដារ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីជំរុញវិស័យទាំងនោះឱ្យចូលក្នុងប្រព័ន្ធ ព្រមទាំងលើកទឹកចិត្ត និងថែរក្សាអោយវិស័យទាំងនោះក្លាយជាមូលដ្ឋានចំណូលពន្ធបន្ថែម;
- បន្តចរចាជាមួយបណ្តាប្រទេសនានា ព្រមទាំងរដ្ឋសមាជិកអាស៊ាន, អាស៊ានបូក ៣ លើការងារកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA);
- ពង្រឹងការប្រមូលចំណូលពន្ធ ជាពិសេសអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឌីជីថល ឬ សេវាឌីជីថល ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក;
- ពង្រឹងការត្រួតពិនិត្យ និងការធ្វើសវនកម្មចំពោះសហគ្រាសដែលជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងវិស័យដែលមានសក្តានុពល និងមានហានិភ័យខ្ពស់ និងពង្រឹងយន្តការគ្រប់គ្រងចំណូលពន្ធលើវិស័យផលិតស្រាបៀរ និងកេសជ្ជៈ;
- បន្តគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យ និងមូលដ្ឋានគិតពន្ធរបស់អ្នកជាប់ពន្ធ និងផ្សព្វផ្សាយមូលដ្ឋានគិតពន្ធដល់អ្នកជាប់ពន្ធគោលដៅឱ្យបានទៀងទាត់;
- បន្តកែលម្អ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវមុខងារស្នូលទាំង ៣ រួមមាន E-registration, E-filling, និង E-payment ដោយប្រើប្រាស់ថ្នាលបច្ចេកវិទ្យារួម និងបន្តដាក់អនុវត្តផែនការជាតិស្តីពីសវនកម្ម (National

Audit Plan) ដើម្បីកំណត់អត្តសញ្ញាណជាយុទ្ធសាស្ត្រ ក្នុងការវិភាគហានិភ័យ និងពង្រឹងការធ្វើសវនកម្ម ដោយផ្អែកលើកម្រិតហានិភ័យ (Risk-Based Audit); និង

- ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលជំពាក់បំណុលពន្ធ និងពង្រឹងយន្តការតាមដាន និងតឹងទារបំណុលពន្ធ ។

### ■ វិធានការផ្នែកគយ និងរដ្ឋាករ

- បង្កើនប្រសិទ្ធភាពការគ្រប់គ្រងការអនុវត្តអត្រាពន្ធអនុគ្រោះ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការលើកទឹកចិត្តដាក់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋតាមបទប្បញ្ញត្តិជាធរមាន;
- កែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករស្របតាមច្បាប់ និងបទប្បញ្ញត្តិថ្មីៗ;
- បន្តការពិនិត្យលទ្ធភាពពង្រីកការធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងការផ្ទៀងផ្ទាត់សំអាងដើមកំណើតទំនិញ ទៅអង្គភាពគយ និងរដ្ឋាករមូលដ្ឋាន ដោយផ្អែកលើកម្រិតអនុលោមភាពធុរជន និងគោលការណ៍គ្រប់គ្រងហានិភ័យ;
- បន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយ និងកែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និងប្រតិបត្តិការគយ ដោយប្រើប្រាស់ឯកសារទម្រង់អេឡិចត្រូនិក និងកាត់បន្ថយឯកសារជាក្រដាស;
- ជំរុញដាក់ឱ្យប្រើប្រាស់មុខងារហត្ថលេខាឌីជីថល សម្រាប់នីតិវិធីគយ ដើម្បីផ្តល់បន្ថែមនូវសុវត្ថិភាព និងភាពងាយស្រួលក្នុងការផ្ទៀងផ្ទាត់លេខសម្គាល់នៃប្រតិបត្តិការ;
- បន្តពង្រឹងយន្តការធុរជនល្អបំផុត (Best Trader Mechanism), កែលម្អប្រព្រឹត្តកម្មលើកទឹកចិត្ត និងពង្រីកបន្ថែមការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃយន្តការ ព្រមទាំងបន្តជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (Authorized Economic Operator - AEO);
- លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កេន ដោយត្រូវសិក្សា និងពិនិត្យលទ្ធភាពបំពាក់ម៉ាស៊ីនស្កេននៅមាត់ច្រកសំខាន់ៗបន្ថែមទៀតដោយប្រើប្រាស់ថវិការដ្ឋ ដើម្បីគាំទ្រការពង្រឹងអនុលោមភាពដោយរក្សាបាននូវកិច្ចសម្រួលពាណិជ្ជកម្ម;
- ពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធទូទាត់ប្រាក់តាមមធ្យោបាយអេឡិចត្រូនិក (E-Payment) និងបន្តពង្រីកវិសាលភាពនៃធនាគារដៃគូដើម្បីអនុវត្តមុខងារនៃប្រព័ន្ធនេះ;
- ពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ទៅក្រសួង-ស្ថាប័នមួយចំនួនបន្ថែមទៀត; និង
- បន្តពង្រឹងយន្តការភាពជាដៃគូជាមួយវិស័យឯកជន ក្នុងការពិគ្រោះយោបល់ និងដោះស្រាយបញ្ហានានា ។

### ■ វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ

- បន្តជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យកាន់តែមានប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព រួមទាំងការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (E-Payment);

- ត្រួតពិនិត្យលើការប្រមូលចំណូលសួយសារធនធានរ៉ែ ផ្អែកលើការកែសម្រួលអត្រាសួយសារលើតម្លៃផលិតផលរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ;
- បន្តតាមដាន, ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលសួយសារធនធានរ៉ែ ជាមួយនឹងបរិមាណធ្វើអាជីវកម្មជាក់ស្តែងរបស់ក្រុមហ៊ុន ដែលកំពុងប្រកបអាជីវកម្ម តាមរយៈក្រុមការងារអន្តរក្រសួង;
- ជំរុញការអនុវត្តការប្រមូលចំណូលពីឈ្នួលសម្បទានដីសេដ្ឋកិច្ច ដោយផ្អែកលើកិច្ចសន្យា និងគោលការណ៍ គណនាថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ចឡើងវិញ;
- ពន្លឿនការកែសម្រួលប្រកាសអន្តរក្រសួង អំពីការកំណត់ថ្លៃឈ្នួលដីឡើងវិញនៅតំបន់អាជ្ញាបណ្ណធនធានរ៉ែ;
- បន្តជំរុញការអនុវត្តការបង់ចំណូលពីសម្បទានដីសេដ្ឋកិច្ច និងធនធានរ៉ែ តាមរយៈប្រព័ន្ធទូទាត់អេឡិចត្រូនិក (E-Payment) និងបង់ប្រាក់រំដោះឱ្យបានទៀងទាត់ ដោយមានការធ្វើអធិការកិច្ច ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ;
- បន្តតាមដាន និងគ្រប់គ្រងចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ តាមរយៈកិច្ចសន្យាជួល និង ការគណនាតម្លៃជួលថ្មីផ្អែកតាមតម្លៃគិតពន្ធប្រថាប់ត្រាផ្ទេរអចលនទ្រព្យ;
- ដកហូតមកវិញនូវចំនួនហ្វ្រេកង់ដែលមិនប្រើប្រាស់ និងរៀបចំដាក់ដេញថ្លៃឡើងវិញ ដើម្បីកៀរគរចំណូលបន្ថែម;
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពី វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរក្សាឱ្យបាននូវស្ថិរភាពចំណូល;
- បន្តរៀបចំយន្តការទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល តាមរយៈគណៈកម្មការអន្តរក្រសួង; និង
- បន្តពិនិត្យ និងពិភាក្សាលើការកៀរគរប្រភពចំណូលមិនមែនសារពើពន្ធថ្មីៗ បន្ថែមលើមូលដ្ឋានដែលមានស្រាប់ ។

## ខ. ក្របខ័ណ្ឌចំណាយសាធារណៈ

**ក្របខ័ណ្ឌចំណាយសាធារណៈរយៈពេលមធ្យម សម្រាប់ឆ្នាំ ២០២៥-២០២៧** ត្រូវបានរៀបចំឡើងដោយរក្សានូវតុល្យភាពថវិកា ពោលគឺពុំឱ្យមានការប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ, ការគ្រោងចំណាយសាធារណៈសម្រាប់រយៈពេលមធ្យម ត្រូវបានរៀបចំប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដោយផ្តោតចម្បងលើការអភិវឌ្ឍមូលធនមនុស្ស, ការពង្រឹងសមត្ថភាពស្ថាប័ន, ការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ជារចនាសម្ព័ន្ធ និងការបន្តអនុវត្តកម្មវិធីគាំពារសង្គម ព្រមទាំងការអនុវត្តគោលនយោបាយអាទិភាព និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងមានភាពធន់ សម្រាប់កិច្ចអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាល នឹងចាប់គ្រោងឱ្យមានមូលនិធិបម្រុងហិរញ្ញវត្ថុ ចាប់ពីឆ្នាំ ២០២៦ តទៅក្នុងអត្រា ២% នៃចំណូលចរន្តថ្នាក់ជាតិឆ្នាំ N-2 ដើម្បីចាប់កសាងទ្រនាប់ថវិកាឡើងវិញ ។

**សម្រាប់ឆ្នាំ ២០២៥, ចំណាយសរុប ត្រូវបានគ្រោងក្នុងទំហំ ១៧,៨៤% នៃ ផ.ស.ស. ពោលគឺមានកំណើនប្រមាណ ០,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤ ។ សម្រាប់ឆ្នាំ ២០២៦-២០២៧, កញ្ចប់ចំណាយសរុប នឹងគ្រោងឱ្យមានកំណើនសមគួរឡើងវិញ ក្នុងអត្រាជាមធ្យមប្រមាណ ៨,៦% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១៧,៥៩% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៧ ។**

**ចំណាយចរន្ត ត្រូវបានគ្រោងក្នុងទំហំ ១២,៤១% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៥ ដែលមានកំណើនប្រមាណ ០,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤ ។ សម្រាប់ឆ្នាំ ២០២៦-២០២៧, ចំណាយចរន្ត ត្រូវបានគ្រោងឱ្យមានកំណើនសន្សឹមៗ ក្នុងអត្រាជាមធ្យមប្រមាណ ៧,២% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១១,៩៣% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៧ ។** ក្នុងនោះ, ចំណាយបន្ទុកបុគ្គលិក ត្រូវបានគ្រោងឱ្យមានកំណើនជាមធ្យមក្នុងអត្រា ៤,០% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលមធ្យមខាងមុខ ដោយផ្តោតសំខាន់លើការបន្តបង្កើនបៀវត្សអប្បបរមាជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ស្របតាមអត្រាអតិផរណា និងសមិទ្ធកម្មការងារ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព ។ ដោយឡែក, ចំណាយមិនមែនបន្ទុកបុគ្គលិក ត្រូវបានគ្រោងឱ្យមានកំណើនជាមធ្យមប្រមាណ ៥,៧% សម្រាប់ឆ្នាំ ២០២៥-២០២៧ សំដៅរក្សានិរន្តរភាពប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន និងបន្តធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម ព្រមទាំងកសាងទុនបម្រុងថវិកាឡើងវិញ តាមរយៈមូលនិធិបម្រុងហិរញ្ញវត្ថុ ។

**ចំណាយមូលធន ត្រូវបានគ្រោងក្នុងទំហំ ៥,៤២% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៥ ដែលមានកំណើនប្រមាណ ១,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤ ។ សម្រាប់ឆ្នាំ ២០២៦-២០២៧, ចំណាយមូលធន ត្រូវបានគ្រោងឱ្យមានកំណើនខ្ពស់ឡើងវិញ ក្នុងអត្រាជាមធ្យមប្រមាណ ១១,៧% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ៥,៦៦% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៧ ។** កំណើននេះ បានគិតគូពីតម្រូវការចំណាយសម្រាប់ការអភិវឌ្ឍ, រក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច, លើកកម្ពស់ភាពប្រកួតប្រជែង និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច ពោលគឺរាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ទៅលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសតាមរយៈ ៖ ១). ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានគុណភាពខ្ពស់ និង ២). ការបង្កើនបរិមាណ និងគុណភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ។

**ក្នុងនោះ, ចំណាយសរុបថ្នាក់ជាតិ ក្នុងឆ្នាំ ២០២៥ ត្រូវបានគ្រោងក្នុងទំហំ ១៦,៦៥% នៃ ផ.ស.ស. ពោលគឺមានកំណើនប្រមាណ ១,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤ ។ សម្រាប់ឆ្នាំ ២០២៦-២០២៧, ចំណាយសរុបថ្នាក់ជាតិ នឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៨,៥% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១៦,៣៨% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៧ ។** ចំណាយថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធនសម្រាប់ឆ្នាំ ២០២៥-២០២៧ ត្រូវបានគ្រោងវិភាជន៍ទៅតាមវិស័យ ដូចខាងក្រោម ៖

**ចំណាយវិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ១,៦១% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ, សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៧,៦%** សំដៅបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, ការអនុវត្តច្បាប់ស្តីពីវិនិយោគថ្មី, ការគាំទ្រធុរកិច្ចថ្មី, ថ្នាលឌីជីថល និងសេដ្ឋកិច្ចនវានុវត្តន៍ និងត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** ព្រមទាំងការចាប់បង្កើន

ទ្រទ្រង់ថវិកាតាមរយៈមូលនិធិបម្រុងហិរញ្ញវត្ថុ ខណៈត្រៀមកញ្ចប់សម្រាប់ការសងការប្រាក់នៃបំណុលសាធារណៈ និងការបង្វិលសងអាករលើតម្លៃបន្ថែម ។

**ចំណាយវិស័យការពារជាតិ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ២,៦១% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ, សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៤,៣%** សំដៅគាំទ្រការកែទម្រង់ប្រព័ន្ធច្បាប់ និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់សុខុមាលភាព, និងការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈជូនកងកម្លាំងនគរបាលជាតិ ក្នុងបុព្វហេតុជានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ ។

**ចំណាយវិស័យសង្គមកិច្ច ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ៥,២៧% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ, សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ១១,១%** សំដៅបន្តលើកកម្ពស់គុណភាពអប់រំ និងអភិវឌ្ឍជំនាញឆ្លើយតបទៅនឹងទីផ្សារ, ពង្រីកវិសាលភាពនៃការទទួលបានសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពសកល, និងជំរុញអនុវត្តកម្មវិធីគោលនយោបាយជាតិគាំពារសង្គម និងគោលនយោបាយអាទិភាពផ្សេងទៀតលើផ្នែកសង្គមកិច្ច, សាសនា, វប្បធម៌ និងបរិស្ថាន ។

**ចំណាយវិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ៣,៨៧% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ, សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៧,៦%** ដោយផ្តោតសំខាន់លើការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការលើកកម្ពស់ផលិតភាពស្របតាមស្តង់ដា និងតម្រូវការទីផ្សារ, ការអនុវត្ត **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិត ស្បែកជើង និងកាបូបកម្ពុជាឆ្នាំ ២០២២-២០២៧, យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ ២០២៣-២០២៨, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥** និង **គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០** ។ល។

**ចំណាយផ្សេងៗ ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ៣,១០% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ, សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា -២,១%** ដែលជាទំហំមួយសមស្រប ក្នុងការផ្តល់លទ្ធភាព និងភាពបត់បែនខ្ពស់ដល់រាជរដ្ឋាភិបាល ក្នុងការបំពេញតម្រូវការចំណាយមានមុខសញ្ញា និងការឆ្លើយតបទៅនឹងតម្រូវការចំណាយអាទិភាពណាមួយបានទាន់ពេល ក្នុងការដោះស្រាយបញ្ហាសង្គម-សេដ្ឋកិច្ច និងត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយអាទិភាពនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល ដូចជាការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ និងស្បៀងបម្រុង ជាដើម ។ ដោយឡែក, សម្រាប់ការអនុវត្តជាក់ស្តែង, ចំណាយថវិកាដែលបានគ្រោង

ក្នុងផ្នែកចំណាយផ្សេងៗនេះ នឹងត្រូវវិភាជទៅតាមវិស័យទាំង ៤ ខាងលើ ស្របតាមគោលដៅនៃមុខចំណាយនីមួយៗ ។

**ចំណាយសរុបថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ ២០២៥ ត្រូវបានគ្រោងក្នុងទំហំ ២,០៣% នៃ ផ.ស.ស. ដែលរួមបញ្ចូលការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងទំហំ ០,៨៤% នៃ ផ.ស.ស. ។ សម្រាប់ឆ្នាំ ២០២៦-២០២៧, ចំណាយសរុបថ្នាក់ក្រោមជាតិ នឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៨,០% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១,៩៧% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៧** ដើម្បីគាំទ្រដល់ការអភិវឌ្ឍ និងការលើកកម្ពស់គុណភាពនៃសេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី ២ ឆ្នាំ ២០២១-២០៣០ ។

ដើម្បីសម្រេចបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងការងើបវិញនូវកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលចាំបាច់ត្រូវពង្រឹងប្រសិទ្ធភាពថវិកា, ទាំងផ្នែកវិភាជន៍ និងផ្នែកប្រតិបត្តិការ, ដោយឈរលើគោលការណ៍គោរពវិន័យថវិកា ប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ និងឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានា តាមរយៈវិធានការសំខាន់ៗក្នុងការអនុវត្តចំណាយ ២០២៥-២០២៧ ដូចខាងក្រោម៖

- បន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ផ្អែកលើអត្រាអតិផរណា និងសមិទ្ធកម្មការងារ ក្នុងគោលដៅពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ, ទាំងគុណភាព និងប្រសិទ្ធភាពរបស់មន្ត្រីរាជការ, ដោយឈរលើគោលការណ៍គុណាធិបតេយ្យ និងចីរភាពថវិកា;
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី, ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព;
- បន្តអភិវឌ្ឍប្រព័ន្ធអប់រំ និងបង្កើនជំនាញ ស្របតាមតម្រូវការទីផ្សារការងារ និងឌីជីថលភាវូបនីយកម្ម និងពង្រឹងគុណភាពការផ្តល់សេវាសុខាភិបាល រួមទាំង លើកកម្ពស់ប្រព័ន្ធគាំពារសង្គម ដើម្បីទ្រទ្រង់ជីវភាពប្រជាជន, ពិសេសគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ;
- បន្តតម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់, បរិយាប័ន្ន និងចីរភាព តាមរយៈការផ្តល់អាទិភាពទៅលើការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់រចនាសម្ព័ន្ធ, ការអភិវឌ្ឍមូលធនមនុស្ស និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ឌីជីថល, និងបៃតង;
- ការផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការប្រមូលចំណូល ដើម្បីរក្សាតុល្យភាព និងចីរភាពថវិកា តាមរយៈការធ្វើអាទិភាវូបនីយកម្មចំណាយ និងពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ;
- ពិនិត្យ និងវាយតម្លៃហានិភ័យឱ្យបានហ្មត់ចត់ លើការអនុវត្តគម្រោងវិនិយោគសាធារណៈនីមួយៗ ដើម្បីអាចគ្រប់គ្រងលើហានិភ័យដែលអាចកើតមានឡើង និងកាត់បន្ថយចំណាយប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការអនុវត្តថវិកា;
- ពង្រឹងការតាមដាន និងវាយតម្លៃលើការអនុវត្តថវិកា និងការផ្សារភ្ជាប់ថវិកាទៅនឹងសមិទ្ធកម្ម ដើម្បីធានាឱ្យបាននូវតម្លាភាព និងប្រសិទ្ធភាពថវិកា;
- បន្តរក្សាចីរភាពបំណុលរយៈពេលមធ្យម និងវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប តាមរយៈការកំណត់ពិតាននៃការខ្ចីប្រចាំឆ្នាំ, កំណត់សូចនាករបំណុលគន្លឹះសំខាន់ៗ, កំណត់គោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទាន និងធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយ; និង

- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព, ជាពិសេសវិស័យបង្កើនផលិតភាព និងតម្លៃបន្ថែម, ជំរុញការតភ្ជាប់, ពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច ។

## គ. ឱនភាពថវិកា និងហិរញ្ញប្បទាន

**ឱនភាពថវិកាសរុបសម្រាប់ឆ្នាំ ២០២៥-២០២៧** ត្រូវបានរំពឹងទុកថានឹងចាប់ផ្តើមរួមតូច និងជាសន្សឹមៗ ដែលឆ្លុះបញ្ចាំងអំពីការដាក់ចេញនូវ **គោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន** និងស្របតាមវិធានហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញ សំដៅរក្សាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និងចីរភាពបំណុលសាធារណៈរបស់កម្ពុជា នាពេលខាងមុខ ។ **ក្នុងន័យនេះ, ឱនភាពថវិកាក្នុងឆ្នាំ ២០២៥ នឹងស្ថិតក្នុងកម្រិត -២,៧៣% នៃ ផ.ស.ស. ហើយបន្តរួមតូចដល់កម្រិតប្រមាណ -១,៩៨% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៧ ។** បន្ថែមលើនេះ, ហិរញ្ញប្បទានដើម្បីទ្រទ្រង់ឱនភាពថវិកាក្នុងរយៈពេលមធ្យមខាងមុខ នឹងបានមកពីប្រភព ៣ សំខាន់ៗ រួមមាន៖ ១). ហិរញ្ញប្បទានក្រៅប្រទេស ២). មូលនិធិទ្រទ្រង់ថវិកា, និង ៣). ការបោះផ្សាយមូលបត្ររដ្ឋ ។

### តារាងទី ៦៖ តារាងសង្ខេបក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧

| ភាគរយនៃ ផ.ស.ស. | 2024ច្បា. | 2024 កែ. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|
| ចំណូលសរុប | **16.93%** | **15.25%** | **15.11%** | **15.36%** | **15.61%** |
| ចំណូលចរន្ត | 16.30% | 14.62% | 14.52% | 14.85% | 15.15% |
| ចំណាយសរុប | **19.33%** | **18.40%** | **17.84%** | **17.52%** | **17.59%** |
| ចំណាយចរន្ត | 13.48% | 12.72% | 12.41% | 12.07% | 11.93% |
| ចំណាយមូលធន | 5.85% | 5.68% | 5.42% | 5.45% | 5.66% |
| អតិរេកចរន្ត | **2.82%** | **1.90%** | **2.10%** | **2.78%** | **3.22%** |
| សមតុល្យថវិកា | **-2.40%** | **-3.15%** | **-2.73%** | **-2.16%** | **-1.98%** |
| *តម្រូវការហិរញ្ញប្បទាន* | *3.50%* | *4.25%* | *3.89%* | *3.45%* | *3.19%* |
| *ឱនភាពថវិកា* | *2.40%* | *3.15%* | *2.73%* | *2.16%* | *1.98%* |
| *ការទូទាត់ការខ្ចី* | *1.10%* | *1.10%* | *1.16%* | *1.29%* | *1.21%* |
| *ប្រភពហិរញ្ញប្បទាន* | *3.50%* | *4.25%* | *3.89%* | *3.45%* | *3.19%* |
| *ហិរញ្ញប្បទានក្រៅប្រទេស* | *2.91%* | *2.91%* | *3.01%* | *2.95%* | *2.88%* |
| *មូលនិធិទ្រទ្រង់ថវិកា* | *0.36%* | *0.77%* | *0.68%* | *0.32%* | *0.14%* |
| *ការបោះផ្សាយមូលបត្ររដ្ឋ* | *0.23%* | *0.23%* | *0.20%* | *0.18%* | *0.16%* |
| *ប្រាក់បញ្ញើរាជរដ្ឋាភិបាល* | *0.00%* | *0.34%* | *0.00%* | *0.00%* | *0.00%* |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បើទោះស្ថិតក្នុងបរិការណ៍នៃលម្ហថវិកាមានភាពរឹងស្អួត, ស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាត្រូវបានវាយតម្លៃថា នឹងនៅតែបន្តមានភាពរឹងមាំ និងមានស្ថិរភាព ដោយអនុលោមបានទៅតាមយុទ្ធាហិរញ្ញវត្ថុ

សាធារណៈ ដែលបានដាក់ចេញ ។ **ជាក់ស្តែង, អនុបាតយុថ្កាហិរញ្ញវត្ថុសាធារណៈទាំង ៥ របស់កម្ពុជាក្នុងរយៈ-ពេលមធ្យម ត្រូវបានព្យាករថានឹងស្ថិតក្នុងកម្រិតក្រោមអនុបាតគោលដែលបានកំណត់ ។**

**តារាងទី ៧៖ សូចនាករវិធានហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៤-២០២៧**

| សូចនាករ | អនុបាតគោល | 2024ប៉ាន់. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|
| I. យុថ្កាហិរញ្ញវត្ថុសាធារណៈ | | | | | |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | 55% | 19.30% | 19.44% | 19.17% | 18.91% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. | 40% | 19.02% | 18.93% | 18.44% | 17.97% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | 180% | 29.09% | 27.40% | 25.79% | 24.73% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | 15% | 1.81% | 1.93% | 1.96% | 1.85% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ | 18% | 7.76% | 8.84% | 9.14% | 8.72% |
| II. វិធានប្រតិបត្តិ | | | | | |
| ឱនភាពថវិកាសរុប | -5% | -3.15% | -2.73% | -2.16% | -1.98% |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ៥. ហានិភ័យហិរញ្ញវត្ថុសាធារណៈ

**ហានិភ័យហិរញ្ញវត្ថុសាធារណៈ** សំដៅដល់ព្រឹត្តិការណ៍ ឬ ការប៉ះទង្គិចណាមួយ ដែលធ្វើឱ្យការប្រមូលចំណូល សម្រេចបានទាបជាងការគ្រោងទុក និង/ឬ ធ្វើឱ្យទំហំនៃចំណាយសរុបច្រើនជាងការកំណត់ ដែលជាលទ្ធផលធ្វើឱ្យឱនភាពថវិការីកធំ ។ ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុសាធារណៈ រួមមានការវិភាគអំពីមូលដ្ឋាននៃហានិភ័យ, ការប៉ាន់ប្រមាណនូវផលប៉ះពាល់ ព្រមទាំងការរៀបចំ និងអនុវត្តយន្តការចាំបាច់នានា ដើម្បីទប់ស្កាត់, បញ្ចៀស និងកាត់បន្ថយផលប៉ះទង្គិច ដែលអាចកើតចេញពីបណ្តាហានិភ័យទាំងនេះ ។

## ៥.១. ហានិភ័យម៉ាក្រូសេដ្ឋកិច្ច

**ហានិភ័យម៉ាក្រូសេដ្ឋកិច្ច** សំដៅដល់ព្រឹត្តិការណ៍ណាមួយ ដែលបង្កជាផលអវិជ្ជមានដោយផ្ទាល់ និងប្រយោល ដល់កំណើនសេដ្ឋកិច្ចជាតិ ។ ក្នុងនោះ, ភាគច្រើននៃហានិភ័យម៉ាក្រូសេដ្ឋកិច្ច មានប្រភពពីកត្តាខាង-ក្រៅដែលអាចសាយភាយជាផលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា ដែលនឹងអាចធ្វើឱ្យការព្យាករ ក៏ដូចជាក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចកម្ពុជាជារួម មានការផ្លាស់ប្តូរ ។ ជារួម, **ហានិភ័យម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម** មាន ៥ សំខាន់ៗ ដូចបានរៀបរាប់ខាងលើ រួមមាន ៖ (១). ការបន្តថមថយកំណើនសេដ្ឋកិច្ចសកល និងចិន; (២). ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ; (៣). ភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម; (៤). ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម; និង (៥). ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។ ទោះបីជាលទ្ធ-ភាពនៃការកើតឡើងមានកម្រិតខុសៗគ្នា, ហានិភ័យទាំងនេះ នឹងអាចបង្កជាផលប៉ះពាល់មកលើសេដ្ឋកិច្ចកម្ពុជាជារួម, ជាពិសេសបង្អាក់នូវការសម្រេចបាននូវកំណើនដែលបានរំពឹងទុក ។

## ៥.២. ហានិភ័យហិរញ្ញវត្ថុសាធារណៈជាក់លាក់

ហានិភ័យហិរញ្ញវត្ថុសាធារណៈជាក់លាក់ សំដៅដល់ព្រឹត្តិការណ៍ ឬ ផលប៉ះទង្គិច ដែលកើតចេញពីផ្នែកណាមួយនៃវិស័យហិរញ្ញវត្ថុសាធារណៈតែម្តង ដែលអាចនាំឱ្យលម្អៀងថវិកាមានការថមថយ ឬ ឱនភាពថវិកាកាន់តែរីកធំ ។

### ក. គម្លាតរវាងការប្រមូលចំណូលជាក់ស្តែងធៀបនឹងការគ្រោង

ស្ថានភាពមិនប្រាកដប្រជាខ្ពស់នៃសេដ្ឋកិច្ចសកល បន្តដាក់សម្ពាធមកលើការប្រមូលចំណូល ស្របពេលដែលរាជរដ្ឋាភិបាលបាន និងកំពុងដាក់ចេញនូវគោលនយោបាយទ្រទ្រង់ជាបន្តបន្ទាប់ រួមមានការកាត់បន្ថយអត្រា និងការអនុគ្រោះពន្ធ ។ ការណ៍នេះ បង្កឱ្យការប្រមូលចំណូលអាចនឹងមិនសម្រេចបានដូចទៅតាមការគ្រោង និងនាំឱ្យមានការថមថយនូវលទ្ធភាពទ្រទ្រង់ចំណាយសាធារណៈ ។ ដើម្បីកាត់បន្ថយហានិភ័យនេះ, រាជរដ្ឋាភិបាលត្រូវត្រួតពិនិត្យ និងតាមដានជាប្រចាំ ដើម្បីដាក់ចេញនូវវិធានការគន្លឹះ ជាក់ស្តែង និងទាន់ពេល ។

### ខ. ការកើននៃបំណុលសាធារណៈ

ទោះបីមានភាពរឹងមាំ, ទិដ្ឋភាពបំណុលសាធារណៈនៅកម្ពុជា អាចប្រឈមនឹងហានិភ័យមួយចំនួន, ជាពិសេស ការកើននៃថ្លៃដើមហិរញ្ញប្បទាន, ខណៈការណ៍ដែលកម្ពុជាត្រៀមខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDC) នឹងនាំឱ្យបាត់បង់ប្រភពហិរញ្ញប្បទានដែលមានកម្រិតសម្បទានខ្ពស់ ហើយប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ នឹងមានការរួមតូច ។ យ៉ាងណាមិញ, ហានិភ័យបំណុលនេះ ស្ថិតនៅកម្រិតអាចគ្រប់គ្រងបាន ដោយរាជរដ្ឋាភិបាលបានដាក់ចេញនូវ **«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤-២០២៨»** និងអនុលោមតាមវិធានការគន្លឹះទាំង ៩ ក្នុងយុទ្ធសាស្ត្រនេះ ។

### គ. ហានិភ័យពាក់ព័ន្ធទៅនឹងការផ្តល់ឥណទានក្នុងរយៈពេលមធ្យម

ហានិភ័យនេះ អាចកើតឡើង ក្នុងករណីភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកលនៅតែបន្តអូសបន្លាយ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ ក៏ដូចជាលទ្ធភាពសងរបស់ឥណាយិក មករាជរដ្ឋាភិបាលវិញ ។ ការគ្រប់គ្រងការផ្តល់ឥណទានរបស់រដ្ឋ ចាំបាច់ទាមទារឱ្យមានការពិនិត្យឡើងវិញ និងកែសម្រួលប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានរបស់រដ្ឋ ដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល, សហគ្រាសសាធារណៈ, ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឱ្យស្របតាមបរិការណ៍ចាំបាច់ជាក់ស្តែង ព្រមទាំងសិក្សារៀបចំយន្តការវាយតម្លៃឥណាយិក និងពង្រឹងការតាមដានស្ថានភាពហិរញ្ញវត្ថុ និងអាជីវកម្មរបស់ឥណាយិកជាប្រចាំ ។

### ឃ. ការកើតមានឡើងនៃបំណុលយថាហេតុ

បំណុលយថាហេតុ (Contingent Liability) សំដៅដល់កាតព្វកិច្ចហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ឧបត្ថម្ភធន, ទូទាត់សំណង ឬ មានតម្រូវការដោះស្រាយបន្ទាន់ឱ្យខាងតែបាន ។ កាតព្វកិច្ចបំណុលយថាហេតុអាចកើតចេញពីប្រភព ២ សំខាន់ៗ៖ ១). ការធ្វើអន្តរាគមន៍ដល់វិស័យធនាគារ និងហិរញ្ញវត្ថុ និងសហគ្រាសសាធារណៈ ដែលផ្តល់សេវាចាំបាច់ ឬ មានលទ្ធភាពបង្កនូវហានិភ័យជាប្រព័ន្ធ (Systemic Risk); និង ២). ការធានារបស់រដ្ឋបណ្តាលមកពីការធានាជាក់ស្តែងលើគម្រោងវិនិយោគ តាមរយៈការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) ។ បច្ចុប្បន្ន, អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ បាននិងកំពុងសហការជាមួយភាគីពាក់ព័ន្ធ ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យ ក្នុងគោលបំណង វាយតម្លៃកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងបំណុលយថាហេតុ លើគម្រោងវិនិយោគពាក់ព័ន្ធ ។

ក្នុងន័យត្រៀមលក្ខណៈ ក្នុងការកាត់បន្ថយការប៉ះទង្គិចពីហានិភ័យបំណុលយថាហេតុ, រាជរដ្ឋាភិបាល បានដាក់ចេញនូវវិធានការគោលនយោបាយមួយចំនួន រួមមាន៖ ១). ចាប់ផ្តើមអនុវត្តមូលនិធិបម្រុងហិរញ្ញវត្ថុ; ២). ការវិភាជថវិកាក្នុងរង្វង់ ៥% នៃសេវាបំណុលសរុបប្រចាំឆ្នាំ ទៅក្នុងមូលនិធិបម្រុងសម្រាប់ត្រៀមលក្ខណៈ ដោះស្រាយការធានារបស់រដ្ឋ; ៣). ការកំណត់ពិតាននៃការធានាទូទាត់សរុបសម្រាប់គម្រោងថ្មីមិនឱ្យលើសពី ១០% នៃថវិកាជាតិ; ៤). ការប្រើប្រាស់យន្តការស្ថាប័នសម្រាប់ការគ្រប់គ្រងគម្រោង ដើម្បីទប់ស្កាត់ និងបញ្ចៀស ផលប៉ះពាល់ ដែលអាចកើតមានឡើងពីគម្រោង; និង ៥). ការតាមដានជាប្រចាំ និងការពង្រឹងការអនុវត្តច្បាប់ និងយន្តការពាក់ព័ន្ធនានា ដើម្បីវាយតម្លៃ និងបញ្ចៀសការកើតមានឡើងនៃហានិភ័យនេះ ។

## ៥.៣. ហានិភ័យស្ថាប័ន

ហានិភ័យស្ថាប័ន សំដៅដល់បញ្ហាប្រឈម ពាក់ព័ន្ធនឹងសមត្ថភាពស្ថាប័ន និង/ឬ ធនធានមនុស្ស ដែល ធ្វើឱ្យមិនអាចសម្រេចបានតាមគោលដៅថវិកាតាមការកំណត់ ។

### ក. ភាពទុកចិត្តបានក្នុងការរៀបចំក្របខ័ណ្ឌ

ហានិភ័យនេះនឹងកើតឡើង ប្រសិនបើមានចន្លោះប្រហោងជាប្រព័ន្ធក្នុងការវិភាគ និងព្យាករម៉ាក្រូសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុសាធារណៈ រួមមានសមត្ថភាពមន្ត្រីជំនាញនៅមានកម្រិតក្នុងការកំណត់អត្តសញ្ញាណ, វិភាគ ហានិភ័យ និងផលប៉ះពាល់នានា, ភាពមានកម្រិតក្នុងការប្រមូលចងក្រងទិន្នន័យ, ទាំងគុណភាព, វិសាលភាព និងភាពទាន់ពេល ។ ដើម្បីត្រៀមលក្ខណៈឆ្លើយតបទៅនឹងហានិភ័យនេះ, វិធានការដែលត្រូវយកចិត្តទុកដាក់ រួមមាន ៖ ១). ការឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គម; ២). ការ-អភិវឌ្ឍធនធានមនុស្ស សំដៅបង្កើនភាពទុកចិត្តបានក្នុងការរៀបចំក្របខ័ណ្ឌ; និង ៣). ការពង្រឹងតួនាទីរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាស្ថាប័នត្រួតពិនិត្យកណ្តាល (Central Oversight Body) ដើម្បីជួយសម្រួល ដល់ការកំណត់អត្តសញ្ញាណ, ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុសាធារណៈ ទន្ទឹមនឹងការប្រមូលផ្តុំ ជាតុចូលអន្តរកម្មពីភាគីពាក់ព័ន្ធ ដើម្បីពង្រឹងភាពធន់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

### ខ. សមត្ថភាពក្នុងការអនុវត្តក្របខ័ណ្ឌ

ហានិភ័យនេះនឹងអាចកើតឡើង ដោយសារអភិបាលកិច្ចរបស់ស្ថាប័នអនុវត្ត និងការផ្តល់សេវាសាធារណៈ នៅមានកម្រិត, ទាំងការអនុវត្ត, ប្រសិទ្ធភាព, និងតម្លាភាព, ជាពិសេសការប្រមូលចំណូល និងការអនុវត្តចំណាយ ព្រមទាំងសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិមិនទាន់ឆ្លើយតបនឹងល្បឿននៃការធ្វើវិមជ្ឈការមុខងារ ។ ភាពទន់ខ្សោយ នៃយន្តការស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់សម្របសម្រួល, បញ្ហាក្នុងការចែករំលែកទិន្នន័យ និងសង្គតិភាព ទិន្នន័យ, ព្រមទាំងកង្វះក្របខ័ណ្ឌគតិយុត្តគ្រប់ជ្រុងជ្រោយ អាចបន្តជាឧបសគ្គនៃការលើកកម្ពស់ប្រសិទ្ធភាព ក្នុងការអនុវត្តក្របខ័ណ្ឌដែលបានដាក់ចេញ ។ ដើម្បីត្រៀមលក្ខណៈឆ្លើយតបទៅនឹងហានិភ័យនេះ, វិធានការ ដែលត្រូវយកចិត្តទុកដាក់ រួមមាន ៖ ១). ការបន្តពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការកែទម្រង់រដ្ឋបាល សាធារណៈ, ពិសេសការធ្វើឌីជីថលូបនីយកម្ម, និងការពង្រឹងយន្តការត្រួតពិនិត្យ និងវាយតម្លៃ; ២). ការបង្កើន ប្រសិទ្ធភាពនៃការអនុវត្តការងារ និងការលើកកម្ពស់ការទទួលខុសត្រូវនៅថ្នាក់ក្រោមជាតិ; ៣). ការបន្តរៀបចំ

និងកែលម្អក្របខ័ណ្ឌគតិយុត្តចាំបាច់នានា; និង ៤). ការអនុវត្តគោលនយោបាយលើកទឹកចិត្តដល់មន្ត្រីរាជការសាធារណៈ ។

## ៦. សេចក្តីសន្និដ្ឋាន

**«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧»** ត្រូវបានរៀបចំឡើងយ៉ាងគត់មត់ អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០០៤-២០២៥ ក៏ដូចជា **ផែនការយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ ២០១៨-២០២៥** ។ **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧»** ត្រូវបានរៀបចំក្នុងគោលបំណងរួមចំនួនបី គឺ ៖ (១). ជំរុញប្រសិទ្ធភាព និងតម្លាភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ, សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈ; (២). ពង្រឹងភាពធន់សង្គម-សេដ្ឋកិច្ច ដែលមានលទ្ធភាពឆ្លើយតបបានរហ័សទៅនឹងវិបត្តិនាពេលអនាគត; និង (៣). ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ដើម្បីជំរុញសម្ទុះនៃការអភិវឌ្ឍជាតិ ប្រកបដោយចីរភាព និងបរិយាប័ន្ន និងសំដៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០ ។

ក្នុងរយៈពេលមធ្យមទៅមុខ សម្រាប់ឆ្នាំ ២០២៥-២០២៧, ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា នឹងស្ថិតក្នុងនិន្នាការល្អប្រសើរដោយសន្សឹមៗ ក្រោមការថមថយផលប៉ះពាល់នៃវិបត្តិ ដោយសារ ៖ **(១). កត្តាខាងក្រៅ** ដែលឆ្លុះបញ្ចាំងពីតម្រូវការខាងក្រៅ តាមរយៈការរំពឹងទុកនូវការងើបវិញនៃសកម្មភាពសង្គម-សេដ្ឋកិច្ច និងការត្រលប់ទៅរកប្រក្រតីភាពវិញនៃអត្រាអតិផរណា, ទាំងក្នុងបរិការណ៍តំបន់ និងសកល, ស្របពេលដែលស្ថានភាពហិរញ្ញវត្ថុសកលមានភាពប្រសើរ; និង **(២). កត្តាខាងក្នុង** ដែលឆ្លុះបញ្ចាំងពីសមត្ថភាព រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់-គ្រងស្ថិរភាពសង្គម-សេដ្ឋកិច្ច និងការពង្រឹងភាពធន់នៃវិស័យសំខាន់ៗ, ជាពិសេស ការបន្តកសាងមូលដ្ឋានគ្រឹះសេដ្ឋកិច្ចរឹងមាំ ប្រកបដោយបរិយាប័ន្ន សំដៅធ្វើឱ្យល្អប្រសើរឡើងនូវបរិយាកាស និងកិច្ចសម្រួលពាណិជ្ជកម្ម, ការវិនិយោគ និងធុរកិច្ច, ព្រមទាំងការជំរុញ និងការអភិវឌ្ឍឌីជីថលូបនីយកម្ម ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិផងដែរ ។ ផ្អែកលើទស្សនវិស័យនេះ, កំណើនសេដ្ឋកិច្ចជាតិរយៈពេលមធ្យម រំពឹងថានឹងសម្រេចបានក្នុងអត្រាជាមធ្យម ៦,៥% ជាមួយនឹងអត្រាអតិផរណាក្នុងកម្រិតអាចគ្រប់គ្រងបាន ក្នុងរង្វង់ ២,៥% និងការរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់ ក្នុងរង្វង់ ៤ ០៦០ រៀល/ដុល្លារអាមេរិក ។

នៅក្នុងទស្សនវិស័យសេដ្ឋកិច្ចខាងលើ, ការគ្រប់គ្រងស្ថានភាពហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៥-២០២៧ ចាំបាច់ត្រូវមានភាពប្រយ័ត្នប្រយែង និងបុរេសកម្មខ្ពស់ ដោយឈរលើគោលការណ៍ ៖ ១). វិន័យ និងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ, ពោលគឺការចាយវាយឱ្យចំទិសដៅ ហើយផ្តោតលើតម្លៃនៃលុយ; និង ២). កសាងឡើងវិញនូវទ្រនាប់ហិរញ្ញវត្ថុសាធារណៈ សំដៅត្រៀមខ្លួនរួចជាស្រេចទៅនឹងតម្រូវការថវិកាសម្រាប់កិច្ចអភិវឌ្ឍ និងសម្រាប់ការឆ្លើយតបទៅនឹងវិបត្តិជាយថាហេតុ នាពេលអនាគត ។ **ជាមួយនឹងការគិតគូរនេះ, ការប្រមូលចំណូលចរន្តត្រូវបានគ្រោងថានឹងមានកំណើនជាមធ្យម ក្នុងរង្វង់ ១០,៥% សម្រាប់ឆ្នាំ ២០២៥-២០២៧ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៥ មានកំណើន ៨,២% សមមូលនឹង ១៤,៥២% នៃ ផ.ស.ស. ។ ចំណាយសាធារណៈសរុប ត្រូវបានរំពឹងថានឹងមានកំណើនជាមធ្យម ៥,៩% ក្នុងមួយឆ្នាំ ដែលក្នុងនោះ ចំណាយចរន្តសម្រាប់ឆ្នាំ ២០២៥ មានកំណើនប្រមាណ ០,៥% សមមូលនឹង ១៧,៨៤% នៃ ផ.ស.ស. ។ ជាលទ្ធផល, ឱនភាពថវិកានឹងថមថយមកត្រឹមរង្វង់ -២,២៩% នៃ ផ.ស.ស. ជាមធ្យម សម្រាប់ឆ្នាំ ២០២៥-២០២៧ ដែលក្នុង**

**នោះ សម្រាប់ឆ្នាំ ២០២៥ មានទំហំប្រមាណ -២,៧៣% នៃ ផ.ស.ស. ។** ជាមួយនឹងការរំពឹងទុកនៃឱនភាពថវិការយៈពេលមធ្យមនេះ, ស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ត្រូវបានវាយតម្លៃថា នឹងនៅតែបន្តមានភាពរឹងមាំ និងប្រកបដោយចីរភាព ដោយអនុលោមបានទៅតាមយុថ្កាហិរញ្ញវត្ថុសាធារណៈ ពោលគឺ អនុបាតទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ នឹងបន្តស្ថិតនៅក្រោមកម្រិតអនុបាតគោល ហើយការគ្រប់គ្រងបំណុលសាធារណៈនឹងបន្តស្ថិតក្នុង «កម្រិតហានិភ័យទាប» ។ តាមរយៈក្របខ័ណ្ឌខាងលើ, ពិតានថវិកាជារួម នឹងក្លាយជាមូលដ្ឋាន សម្រាប់រៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យម ២០២៥-២០២៧ និង ពិតានថវិកាជាក់លាក់ឆ្នាំ ២០២៥ (ដែលជាឆ្នាំទី ១) នឹងក្លាយជាមូលដ្ឋាននៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ។

ជារួម, ស្ថិតក្នុងស្ថានភាពហ៊ុមព័ទ្ធដោយវិបត្តិជាបន្តបន្ទាប់, រាជរដ្ឋាភិបាល នឹងខិតខំពន្លឿនកម្មវិធីកែទម្រង់សំខាន់ៗ និងដាក់ចេញវិធានការកែទម្រង់មុតស្រួចបន្ថែម ស្របជាមួយនឹងគោលជំហរពុំបង្កើនបន្ទុកពន្ធថ្មី និងការប្តេជ្ញាបន្តអភិវឌ្ឍមូលធនមនុស្ស, ការពង្រឹងសមត្ថភាពស្ថាប័ន, ការកែទម្រង់រដ្ឋបាលសាធារណៈ, ការចាប់យកកាលានុវត្តភាពថ្មីៗ ដែលកើតចេញពីការប្រែប្រួលនិន្នាការសកល និងការបន្តអនុវត្តគោលនយោបាយអាទិភាព សំដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព, បរិយាប័ន្ន និងភាពធន់ ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ក៖ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៧

| សូចនាករ | ២០២១ | ២០២២ | ២០២៣ប | ២០២៤ព្យ | ២០២៥ព្យ | ២០២៦ព្យ | ២០២៧ព្យ |
|---|---|---|---|---|---|---|---|
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | 150,793 | 164,059 | 177,036 | 192,005 | 209,163 | 228,495 | 250,078 |
| ផ.ស.ស. សម្រាប់ម្នាក់ (ដុល្លារអាមេរិក) | 2,234 | 2,383 | 2,520 | 2,713 | 2,924 | 3,162 | 3,417 |
| កំណើន ផ.ស.ស. ពិត (%) | 3.1% | 5.1% | 5.0% | 6.0% | 6.3% | 6.5% | 6.7% |
| អត្រាបរិត្តិផរណា ផ.ស.ស. (កំណើនប្រចាំឆ្នាំ) | 2.6% | 3.5% | 2.8% | 2.3% | 2.5% | 2.5% | 2.5% |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | 2.9% | 5.3% | 2.1% | 2.7% | 2.5% | 2.5% | 2.5% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាមេរិក) | 4,068 | 4,087 | 4,110 | 4,083 | 4,069 | 4,056 | 4,054 |
| ការនាំចេញ (%នៃ ផ.ស.ស.) | 52.7% | 57.7% | 54.7% | 55.0% | 57.2% | 59.0% | 60.9% |
| ការនាំចូល (%នៃ ផ.ស.ស.) | -82.9% | -79.7% | -61.6% | -64.8% | -69.1% | -72.5% | -75.3% |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផ.ស.ស.) | -30.4% | -22.0% | -6.9% | -9.8% | -11.9% | -13.5% | -14.4% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃ ផ.ស.ស.) | -29.4% | -18.9% | 1.3% | -1.5% | -2.6% | -3.8% | -4.8% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | 20,265 | 17,805 | 19,998 | 22,303 | 24,423 | 26,604 | 28,576 |
| ចំនួនខែនៃការនាំចូល | 7.4 | 6.1 | 8.2 | 8.0 | 7.5 | 7.2 | 6.8 |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា (វិស័យខាងក្រៅឆ្នាំ ២០២៣) និងការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ឧបសម្ព័ន្ធ ខ៖ ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ឆ្នាំ ២០២៣-២០២៧

## ខ១. ជាប៊ីលានរៀល

| សូចនាករ | 2023ប. | 2024ច្ប. | 2024ប៉ាន់. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|---|
| ចំណូលសរុប | 34,901 | 32,509 | 29,285 | 31,602 | 35,098 | 39,039 |
| ចំណូលចរន្តសរុប | 26,891 | 31,305 | 28,075 | 30,365 | 33,939 | 37,897 |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 9,166 | 11,118 | 9,450 | 10,146 | 11,140 | 12,249 |
| អគ្គនាយកដ្ឋានពន្ធដារ | 14,617 | 16,856 | 15,170 | 16,272 | 18,359 | 20,663 |
| ចំណូលមិនមែនសារពើពន្ធ | 3,107 | 3,331 | 3,454 | 3,947 | 4,440 | 4,984 |
| ចំណូលមូលធន | 8,010 | 1,204 | 1,211 | 1,236 | 1,160 | 1,142 |
| ចំណាយសរុប | 36,288 | 37,110 | 35,335 | 37,305 | 40,040 | 43,987 |
| ចំណាយចរន្តសរុប | 22,152 | 25,884 | 24,431 | 25,964 | 27,576 | 29,839 |
| បន្ទុកបុគ្គលិក | 10,503 | 11,188 | 11,194 | 11,595 | 12,070 | 12,577 |
| បន្ទុកមិនមែនបុគ្គលិក | 11,649 | 14,695 | 13,237 | 14,369 | 15,505 | 17,261 |
| ចំណាយមូលធនសរុប | 14,136 | 11,227 | 10,905 | 11,341 | 12,464 | 14,149 |
| ហិរញ្ញប្បទានក្នុងប្រទេស | 6,613 | 5,019 | 4,697 | 4,470 | 5,212 | 6,484 |
| ហិរញ្ញប្បទានក្រៅប្រទេស | 5,865 | 6,208 | 6,208 | 6,871 | 7,252 | 7,665 |
| អតិរេកចរន្ត | 4,738 | 5,421 | 3,647 | 4,402 | 6,363 | 8,058 |
| ឱនភាពថវិកា | -9,117 | -4,601 | -6,050 | -5,703 | -4,942 | -4,948 |

## ខ២. កំណើនប្រចាំឆ្នាំ

| សូចនាករ | 2023ប. /2022 | 2024ច្ប. /2023ប. | 2024ប៉ាន់. /2023ប. | 2025ព្យ. /2024ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|---|
| ចំណូលសរុប | 0.0% | -6.9% | -16.1% | 7.9% | 11.1% | 11.2% |
| ចំណូលចរន្តសរុប | -2.1% | 16.4% | 4.4% | 8.2% | 11.8% | 11.7% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | -16.4% | 21.3% | 3.1% | 7.4% | 9.8% | 10.0% |
| អគ្គនាយកដ្ឋានពន្ធដារ | 7.3% | 15.3% | 3.8% | 7.3% | 12.8% | 12.6% |
| ចំណូលមិនមែនសារពើពន្ធ | 8.5% | 7.2% | 11.2% | 14.3% | 12.5% | 12.3% |
| ចំណូលមូលធន | 7.7% | -85.0% | -84.9% | 2.1% | -6.2% | -1.5% |
| ចំណាយសរុប | 12.1% | 2.3% | -2.6% | 5.6% | 7.3% | 9.9% |
| ចំណាយចរន្តសរុប | 10.9% | 16.8% | 10.3% | 6.3% | 6.2% | 8.2% |
| បន្ទុកបុគ្គលិក | 10.1% | 6.5% | 6.6% | 3.6% | 4.1% | 4.2% |
| បន្ទុកមិនមែនបុគ្គលិក | 11.6% | 26.2% | 13.6% | 8.6% | 7.9% | 11.3% |
| ចំណាយមូលធនសរុប | 14.0% | -20.6% | -22.9% | 4.0% | 9.9% | 13.5% |
| ហិរញ្ញប្បទានក្នុងប្រទេស | 23.9% | -24.1% | -29.0% | -4.8% | 16.6% | 24.4% |
| ហិរញ្ញប្បទានក្រៅប្រទេស | 4.6% | 5.9% | 5.9% | 10.7% | 5.5% | 5.7% |

## ខ៣. ជាភាគរយនៃ ផ.ស.ស.

| សូចនាករ | 2023ប. | 2024ច្ប. | 2024ប៉ាន់. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
| --- | --- | --- | --- | --- | --- | --- |
| ចំណូលសរុប | 19.71% | 16.93% | 15.25% | 15.11% | 15.36% | 15.61% |
| ចំណូលចរន្តសរុប | 15.19% | 16.30% | 14.62% | 14.52% | 14.85% | 15.15% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 5.18% | 5.79% | 4.92% | 4.85% | 4.88% | 4.90% |
| អគ្គនាយកដ្ឋានពន្ធដារ | 8.26% | 8.78% | 7.90% | 7.78% | 8.03% | 8.26% |
| ចំណូលមិនមែនសារពើពន្ធ | 1.76% | 1.73% | 1.80% | 1.89% | 1.94% | 1.99% |
| ចំណូលមូលធន | 4.52% | 0.63% | 0.63% | 0.59% | 0.51% | 0.46% |
| ចំណាយសរុប | 20.50% | 19.33% | 18.40% | 17.84% | 17.52% | 17.59% |
| ចំណាយចរន្តសរុប | 12.51% | 13.48% | 12.72% | 12.41% | 12.07% | 11.93% |
| បន្ទុកបុគ្គលិក | 5.93% | 5.83% | 5.83% | 5.54% | 5.28% | 5.03% |
| បន្ទុកមិនមែនបុគ្គលិក | 6.58% | 7.65% | 6.89% | 6.87% | 6.79% | 6.90% |
| ចំណាយមូលធនសរុប | 7.98% | 5.85% | 5.68% | 5.42% | 5.45% | 5.66% |
| ហិរញ្ញប្បទានក្នុងប្រទេស | 3.74% | 2.61% | 2.46% | 2.14% | 2.28% | 2.59% |
| ហិរញ្ញប្បទានក្រៅប្រទេស | 3.31% | 3.23% | 3.23% | 3.29% | 3.17% | 3.07% |
| អតិរេកចរន្ត | 2.68% | 2.82% | 1.90% | 2.10% | 2.78% | 3.22% |
| ឱនភាពថវិកា | -5.15% | -2.40% | -3.15% | -2.73% | -2.16% | -1.98% |

# ឧបសម្ព័ន្ធ គ៖ ការវិភាគចំណាយថ្នាក់ជាតិតាមវិស័យ

## គ១. ជាប៊ីលានរៀល

| សូចនាករ | 2023ប. | 2024ច្ប. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|
| ចំណាយសរុបថ្នាក់ជាតិ | 33,854 | 34,497 | 34,827 | 37,334 | 40,961 |
| វិស័យរដ្ឋបាលទូទៅ | 3,584 | 3,173 | 3,435 | 3,666 | 3,956 |
| ចំណាយចរន្ត | 3,408 | 2,987 | 3,002 | 3,221 | 3,499 |
| ចំណាយមូលធន | 176 | 186 | 433 | 445 | 457 |
| វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 5,132 | 5,488 | 5,702 | 5,947 | 6,232 |
| ចំណាយចរន្ត | 5,102 | 5,454 | 5,680 | 5,912 | 6,179 |
| ចំណាយមូលធន | 30 | 34 | 22 | 35 | 53 |
| វិស័យសង្គមកិច្ច | 8,943 | 9,796 | 10,810 | 12,030 | 13,451 |
| ចំណាយចរន្ត | 8,402 | 9,211 | 9,620 | 10,784 | 12,069 |
| ចំណាយមូលធន | 541 | 585 | 1,190 | 1,246 | 1,382 |
| វិស័យសេដ្ឋកិច្ច | 7,482 | 7,888 | 8,006 | 8,857 | 9,799 |
| ចំណាយចរន្ត | 1,658 | 1,756 | 1,754 | 1,824 | 1,922 |
| ចំណាយមូលធន | 5,823 | 6,132 | 6,252 | 7,032 | 7,878 |
| ចំណាយផ្សេងៗ | 8,714 | 8,152 | 6,874 | 6,834 | 7,523 |
| ចំណាយចរន្ត | 1,661 | 4,398 | 3,926 | 3,669 | 3,749 |
| ចំណាយមូលធន | 7,053 | 3,754 | 2,948 | 3,165 | 3,774 |

## គ២. កំណើនប្រចាំឆ្នាំ

| សូចនាករ | 2023ច្ប. /2022 | 2023ប. /2022 | 2024ច្ប. /2023ប. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|---|
| ចំណាយសរុបថ្នាក់ជាតិ | 22.6% | 13.4% | 1.9% | 1.0% | 7.2% | 9.7% |
| វិស័យរដ្ឋបាលទូទៅ | 15.4% | 34.3% | -11.5% | 8.3% | 6.7% | 7.9% |
| ចំណាយចរន្ត | 14.2% | 37.0% | -12.4% | 0.5% | 7.3% | 8.6% |
| ចំណាយមូលធន | 32.8% | -2.0% | 5.9% | 132.7% | 2.6% | 2.8% |
| វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 6.8% | 5.1% | 6.9% | 3.9% | 4.3% | 4.8% |
| ចំណាយចរន្ត | 6.8% | 6.8% | 6.9% | 4.2% | 4.1% | 4.5% |
| ចំណាយមូលធន | 4.5% | -72.4% | 14.4% | -35.9% | 59.0% | 51.8% |
| វិស័យសង្គមកិច្ច | 10.8% | 10.2% | 9.5% | 10.4% | 11.3% | 11.8% |
| ចំណាយចរន្ត | 11.4% | 18.1% | 9.6% | 4.4% | 12.1% | 11.9% |
| ចំណាយមូលធន | 6.3% | -45.9% | 8.1% | 103.5% | 4.7% | 10.9% |
| វិស័យសេដ្ឋកិច្ច | 10.8% | 17.7% | 5.4% | 1.5% | 10.6% | 10.6% |
| ចំណាយចរន្ត | 4.4% | 9.4% | 5.9% | -0.1% | 4.0% | 5.3% |
| ចំណាយមូលធន | 12.8% | 20.3% | 5.3% | 2.0% | 12.5% | 12.0% |
| ចំណាយផ្សេងៗ | 56.8% | 11.3% | -6.4% | -15.7% | -0.6% | 10.1% |
| ចំណាយចរន្ត | 70.0% | -16.6% | 164.7% | -10.7% | -6.5% | 2.2% |
| ចំណាយមូលធន | 52.3% | 20.9% | -46.8% | -21.5% | 7.4% | 19.2% |

## គ៣. ជាភាគរយនៃ ផ.ស.ស.

| សូចនាករ | 2023ច្បា. | 2023កែ. | 2024ប៉ាន់. | 2025ព្យ. | 2026ព្យ. | 2027ព្យ. |
|---|---|---|---|---|---|---|
| ចំណាយសរុបថ្នាក់ជាតិ | 20.68% | 19.12% | 17.97% | 16.65% | 16.34% | 16.38% |
| វិស័យរដ្ឋបាលទូទៅ | 1.74% | 2.02% | 1.65% | 1.64% | 1.60% | 1.58% |
| ចំណាយចរន្ត | 1.60% | 1.93% | 1.56% | 1.44% | 1.41% | 1.40% |
| ចំណាយមូលធន | 0.13% | 0.10% | 0.10% | 0.21% | 0.19% | 0.18% |
| វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 2.95% | 2.90% | 2.86% | 2.73% | 2.60% | 2.49% |
| ចំណាយចរន្ត | 2.88% | 2.88% | 2.84% | 2.72% | 2.59% | 2.47% |
| ចំណាយមូលធន | 0.06% | 0.02% | 0.02% | 0.01% | 0.02% | 0.02% |
| វិស័យសង្គមកិច្ច | 5.08% | 5.05% | 5.10% | 5.17% | 5.26% | 5.38% |
| ចំណាយចរន្ត | 4.48% | 4.75% | 4.80% | 4.60% | 4.72% | 4.83% |
| ចំណាយមូលធន | 0.60% | 0.31% | 0.30% | 0.57% | 0.55% | 0.55% |
| វិស័យសេដ្ឋកិច្ច | 3.98% | 4.23% | 4.11% | 3.83% | 3.88% | 3.92% |
| ចំណាយចរន្ត | 0.89% | 0.94% | 0.91% | 0.84% | 0.80% | 0.77% |
| ចំណាយមូលធន | 3.09% | 3.29% | 3.19% | 2.99% | 3.08% | 3.15% |
| ចំណាយផ្សេងៗ | 6.93% | 4.92% | 4.25% | 3.29% | 2.99% | 3.01% |
| ចំណាយចរន្ត | 1.91% | 0.94% | 2.29% | 1.88% | 1.61% | 1.50% |
| ចំណាយមូលធន | 5.02% | 3.98% | 1.96% | 1.41% | 1.39% | 1.51% |